BNKC MFI

# ២០២៣

# របាយការណ៍ប្រចាំឆ្នាំ

# របាយការណ៍
# ប្រចាំឆ្នាំ

# ២០២៣

# មាតិកា

## អំពីក្រុមហ៊ុន

តួលេខសំខាន់ៗ ០៨
ព័ត៌មានគ្រឹះស្ថាន ០៩
ព្រឹត្តិការណ៍សំខាន់ៗ របស់ប៊ីអេនខេស៊ី ១០
ភាគទុនិក ១២
ក្រុមប្រឹក្សាភិបាល ១៣
ទស្សនវិស័យ | បេសកកម្ម | គោលដៅយុទ្ធសាស្ត្រ ១៤
ចំណាប់អារម្មណ៍របស់អគ្គនាយកប្រតិបត្តិ ១៥

## ប្រតិបត្តិការរបស់យើង

សាខា ១៨
ផលិតផល ២០
អតិថិជន ប៊ីអេនខេស៊ី ២២
កម្មវិធីទូរសព្ទដៃ « BNKC Mobile App » ២៣

## ក្រុមការងាររបស់យើង

រចនាសម្ព័ន្ធគ្រឹះស្ថាន ២៦
គណៈគ្រប់គ្រងកំពូល ២៧
គណៈគ្រប់គ្រង ៣២

## សកម្មភាពរបស់យើង

ការអភិវឌ្ឍសមត្ថភាពបុគ្គលិក ៣៨
គោលការណ៍ការពារអតិថិជន ៤២
ទស្សនកិច្ចរបស់អគ្គនាយកក្រុមហ៊ុន BNK Financial Group ៤៤
ទំនួលខុសត្រូវផ្នែកសង្គម ៤៦
វិញ្ញាបនបត្រអនុលោមភាពសារពើពន្ធ ៤៨

## របាយការណ៍សវនកម្មឯករាជ្យ

របាយការណ៍សវនកម្មឯករាជ្យ ៥២

# អំពីក្រុមហ៊ុន



BNK
គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេនខេស៊ី (ខេមបូឌា) ភីអិលស៊ី
BNKC (Cambodia) Microfinance Institute Plc.
Tel: 023-213-900
ទីស្នាក់ការកណ្តាល
Head Office

# តួលេខសំខាន់ៗ

## សាខា




## បុគ្គលិក




## អតិថិជន




## សមតុល្យផលប័ត្រឥណទានសរុប

(US$, Thousand)



# ព័ត៌មានគ្រឹះស្ថាន




**២០** សាខា

**តំបន់ប្រតិបត្តិការ**

**១៦** ខេត្ត

**៦៥៣** ឃុំ

**២,៨៦២** ភូមិ

**១០,០៣០** អតិថិជន

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេនខេស៊ី (ខេមបូឌា) ភីអិលស៊ី** ដែលមានឈ្មោះដើមថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ខេប៊ីអេសស៊ី (ខេមបូឌា) ភីអិលស៊ី ជាសាជីវកម្មទទួលខុសត្រូវមានកម្រិត ដែលបានបង្កើតឡើង នៅថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៤ ហើយបានទទួលអាជ្ញាប័ណ្ណពីធនាគាជាតិនៃកម្ពុជា នៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៥។ គ្រឹះស្ថាន ទទួលបានការវិនិយោគ ១00% ពីក្រុមហ៊ុនមេ BNK Capital Co,. Ltd. មានមូលដ្ឋាន នៅទីក្រុងប៊ូសាន នៃសាធារណរដ្ឋកូរ៉េ នូវដើមទុនចំនួន ២០លានដុល្លារ សហរដ្ឋអាមេរិក។ គោលបំណងចំបង របស់គ្រឹះស្ថាន គឺផ្ដល់សេវាហិរញ្ញវត្ថុ ដ៏ល្អបំផុត ជូនប្រជាជនកម្ពុជា ប្រកបដោយ ទំនួលខុសត្រូវ និងតម្លាភាព។ លើសពីនេះ ទៅទៀត គ្រឹះស្ថាន មានគោលជំហរ ចូលរួមចំណែកយ៉ាងសកម្ម ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា តាមរយៈ ការសម្របសម្រួលផ្នែកហិរញ្ញវត្ថុ និងការរួមចំណែកក្នុងសង្គម ក៏ដូចជាផ្ដល់នូវឱកាសការងារ ជូនដល់និយោជិត ដែលមានបំណងចង់អភិវឌ្ឍសមត្ថភាព និងជំនាញ ឲ្យចូលរួមបម្រើការងារក្នុងគ្រឹះស្ថាន ដើម្បីភាពរីកចម្រើននាពេលអនាគត។



# ព្រឹត្តិការណ៍សំខាន់ៗ របស់ ប៊ីអេនខេស៊ី

**២០១៤**
បង្កើតគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ខេប៊ីអេសស៊ី (ខេមបូឌា) ភីអិលស៊ី

**២០១៥**
ទទួលអាជ្ញាបណ្ណជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ពីធនាគារជាតិនៃកម្ពុជា

**២០១៦**
ការិយាល័យកណ្ដាល ទទួលបានអាជ្ញាបណ្ណផ្លូវការពី ធនាគារជាតិនៃកម្ពុជា

ប្ដូរឈ្មោះក្រុមហ៊ុនទៅ « គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេនខេស៊ី (ខេមបូឌា) ភីអិលស៊ី »

សាខាស្រុកអង្គស្នួល ទទួលបានអាជ្ញាបណ្ណផ្លូវការពី ធនាគារជាតិនៃកម្ពុជា

សាខាក្រុងច្បារមន ទទួលបានអាជ្ញាបណ្ណផ្លូវការពី ធនាគារជាតិនៃកម្ពុជា

**២០១៧**

**២០១៨**
សាខាស្រុកត្រាំកក់ ទទួលបានអាជ្ញាបណ្ណផ្លូវការពី ធនាគារជាតិនៃកម្ពុជា

មានដើមទុនសរុបចំនួន ១៥លានដុល្លារ សហរដ្ឋអាមេរិក

**២០១៩**

សាខាស្រុកឧដុង្គ
ទទួលបានអាជ្ញាបណ្ណផ្លូវការពី
ធនាគារជាតិនៃកម្ពុជា

សាខាខេត្តសៀមរាប
ទទួលបានអាជ្ញាបណ្ណផ្លូវការពី
ធនាគារជាតិនៃកម្ពុជា

សាខាខេត្តបាត់ដំបង
ទទួលបានអាជ្ញាបណ្ណផ្លូវការពី
ធនាគារជាតិនៃកម្ពុជា

**២០២០**

សាខាស្រុកកណ្ដាលស្ទឹង
ស្រុកខ្សាច់កណ្ដាល និង
ស្រុកឈូក
ទទួលបានអាជ្ញាបណ្ណផ្លូវការពី
ធនាគារជាតិនៃកម្ពុជា

**២០២១**

បើកដំណើការ
កម្មវិធីទូរស័ព្ទដៃ
« BNKC Mobile App »

សាខាស្រុកជើងព្រៃ
ក្រុងកំពត
ក្រុងប៉ោយប៉ែត និង
ក្រុងសិរីសោភ័ណ
ទទួលបានអាជ្ញាបណ្ណផ្លូវការពី
ធនាគារជាតិនៃកម្ពុជា

**២០២២**

ទទួលបម្រើអតិថិជន
លើសពី ១០,០០០នាក់

មានដើមទុនសរុបចំនួន
២០លានដុល្លារ
សហរដ្ឋអាមេរិក

សាខាស្រុកថ្ពង
ស្រុកបាទី
ស្រុកពាមរក៍
ស្រុកសំរោង និង
ស្រុកស្វាយអន្ទរ
ទទួលបានអាជ្ញាបណ្ណផ្លូវការពី
ធនាគារជាតិនៃកម្ពុជា

**២០២៣**

ទទួលបានកម្រិតអនុលោម
ភាពសារពើពន្ធប្រភេទ៖ មាស

បង្កើតនាយកដ្ឋាន
គ្រប់គ្រងហានិភ័យ

ទស្សនកិច្ចរបស់
អគ្គនាយកក្រុមហ៊ុន
BNK Financial Group
មកកាន់ប្រទេសកម្ពុជា

ផ្លាស់ប្ដូរទីតាំងប្រតិបត្តិការ
សាខាចំនួន ៣

# ភាគទុនិក

BNK Capital



**១00%**
**ការវិនិយោគ**

ក្រុមហ៊ុន ប៊ីអេនខេ ខាប់ភីតាល់ គឺជាក្រុមហ៊ុនគ្រួសារ ជាមួយធនាគារប៊ូសាន និងធនាគារយ៉ុងណាំ ជាក្រុមហ៊ុនបុត្រសម្ព័ន្ធនៃ BNK Financial Group ដែលផ្តល់ជូននូវ ផលិតផល និងសេវាកម្មផ្នែកហិរញ្ញវត្ថុជាច្រើនប្រភេទ រួមមាន ឥណទានយានយន្ត (បង់រំលស់ ជួលកម្ចី) ឥណទានផ្ទាល់ខ្លួន ឥណទានដាក់ទ្រព្យធានា បង់រំលស់សម្ភារៈប្រើប្រាស់ និងហិរញ្ញវត្ថុសាជីវកម្មជាដើម។ល។

ក្រុមហ៊ុន ប៊ីអេនខេ ខាប់ភីតាល់ ត្រូវបានបង្កើតឡើងតាំងពីឆ្នាំ២០១០ ហើយបាន អភិវឌ្ឍន៍ខ្លួនជាក្រុមហ៊ុនមូលធន ពណ៌ខៀវ (Blue-Chip) ដែលតំណាងឱ្យបណ្តាញអាជីវកម្មទូទាំងប្រទេស ហើយមានទ្រព្យសម្បត្តិ ប្រតិបត្តិការ រហូតដល់ទៅ ៣លានលានវ៉ុន ក្នុងរយៈពេលត្រឹមតែ ៤ឆ្នាំ ប៉ុណ្ណោះ។

ប៊ីអេនខេ ខាប់ភីតាល់ រក្សាយ៉ាងខ្ជាប់ខ្ជួន នូវការតាំងចិត្ត ក្នុងការបំពេញតម្រូវការ ហិរញ្ញវត្ថុចម្រុះ របស់អតិថិជន។ លើសពីនេះ ក្រុមហ៊ុន ប៊ីអេនខេ ខាប់ភីតាល់ បានបង្កើតក្រុមហ៊ុនបុត្រសម្ព័ន្ធ ចំនួន៦ នៅក្នុងប្រទេស ចំនួន៥ នៅអាស៊ីអាគ្នេយ៍ និងអាស៊ីកណ្តាល ហើយយើងកំពុងអភិវឌ្ឍអាជីវកម្មឯកទេស សម្រាប់ប្រទេសនីមួយៗ។

ក្រុមហ៊ុន ប៊ីអេនខេ ខាប់ភីតាល់ ផ្តល់នូវការច្នៃប្រឌិត ឌីជីថល ដែលផ្តោតលើអតិថិជន និងការបង្កើន សមត្ថភាពសេវាកម្ម។ ការកសាងផលប័ត្រ ដែលមានតុល្យភាព សូម្បីតែនៅក្នុងបរិយាកាសហិរញ្ញវត្ថុ ដែលផ្លាស់ប្តូរយ៉ាងឆាប់រហ័សក៏ដោយ យើងកំពុងទទួលបានកំណើនផលប័ត្រឥណទាន ជាបន្តបន្ទាប់។ យើងប្តេជ្ញាបង្កើត នូវសេវាកម្មហិរញ្ញវត្ថុជាច្រើនប្រភេទ ដោយផ្អែកលើធនធានមនុស្ស ប្រកបដោយវិជ្ជាជីវៈ និងចំណេះដឹងផ្នែកហិរញ្ញវត្ថុ ហើយខិតខំប្រឹងប្រែង ឱ្យអស់ពីសមត្ថភាព ដើម្បីផ្តល់ជូន អតិថិជននូវសេវាកម្មហិរញ្ញវត្ថុ ប្រកបដោយប្រសិទ្ធភាព និងភាពច្នៃប្រឌិត។



**៣៨០**
**ពាន់លាន**
**ដើមទុនបានចុះបញ្ជី**
**(KWR)**

ក្រុមហ៊ុន ប៊ីអេនខេ ខាប់ភីតាល់ ក៏មានឆន្ទៈ ក្នុងការក្លាយជាក្រុមហ៊ុនមួយ ដែលផ្តល់អាទិភាព ទៅលើសេចក្តីពេញចិត្ត របស់អតិថិជន ជាក្រុមហ៊ុន ដែលយកចិត្តទុកដាក់ខ្លាំងលើការលើកកម្ពស់ សុខុមាលភាពសង្គម និងផ្តល់ការលើកទឹកចិត្ត ទៅដល់បុគ្គលិករបស់ខ្លួន។ ក្រុមហ៊ុនបានដាក់ចេញ នូវរាល់កិច្ចខិតខំប្រឹងប្រែង ដើម្បីក្លាយជាក្រុមហ៊ុនហិរញ្ញវត្ថុដ៏ល្អបំផុត ដែលមានសមត្ថភាព ជាស្ថាប័នហិរញ្ញវត្ថុ ឈានមុខគេក្នុង និងក្រៅប្រទេសនាពេលអនាគត ស្របតាមចក្ខុវិស័យ គ្រប់គ្រងកម្រិតមធ្យម / រយៈពេលវែងរបស់ BNK Financial Group « ជាក្រុមហ៊ុនហិរញ្ញវត្ថុ ឈានមុខគេលើពិភពលោក / ក្នុងតំបន់ »។

# ក្រុមប្រឹក្សាភិបាល



លោក NOH SANGHUN

ប្រធានក្រុមប្រឹក្សាភិបាល



លោក LEE SIHYUN

សមាជិកក្រុមប្រឹក្សាភិបាល



លោក PARK BYOUNGSOO

សមាជិកក្រុមប្រឹក្សាភិបាល



លោក LEE SUKYEOP

សមាជិកក្រុមប្រឹក្សាភិបាល



លោក IV POLY

សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ

# ទស្សនវិស័យ បេសកកម្ម គោលដៅយុទ្ធសាស្ត្រ

## គោលដៅយុទ្ធសាស្ត្រ

- បង្កើនសុចរិតភាព និងប្រាក់ចំណេញ
- បង្កើតផលិតផល ដែលច្បាស់លាស់ និងពង្រីកតំបន់ទីផ្សារ
- បង្កើនគុណភាពនៃទ្រព្យសកម្មដោយពង្រឹងការគ្រប់គ្រងហានិភ័យ

## ទស្សនវិស័យ

ផ្តល់នូវសេវាកម្មផ្នែកហិរញ្ញវត្ថុល្អឈានមុខគេ ដល់ប្រជាជនកម្ពុជា ឱ្យមានការរីកចម្រើនប្រកបដោយនិរន្តរភាព។

## បេសកកម្ម

លើកស្ទួយកម្រិតជីវភាពរបស់ប្រជាពលរដ្ឋក្នុងប្រទេសកម្ពុជា ពង្រឹងតម្លៃ របស់អតិថិជន បុគ្គលិក ម្ចាស់ភាគហ៊ុន និងសង្គមជាតិ តាមរយៈការផ្តល់នូវសេវាកម្មហិរញ្ញវត្ថុដ៏ល្អបំផុត។

# ចំណាប់អារម្មណ៍របស់ អគ្គនាយកប្រតិបត្តិ



**លោក LEE SIHYUN**
**អគ្គនាយកប្រតិបត្តិ**

ជម្រាបសួរ! ខ្ញុំបាទ LEE SIHYUN ជាអគ្គនាយកប្រតិបត្តិ របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេនខេស៊ី (ខេមបូឌា) ភីអិលស៊ី។

ជាដំបូង ខ្ញុំសូមថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅ ចំពោះអតិថិជន ដែលតែងតែគាំទ្រ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេនខេស៊ី (ខេមបូឌា) ភីអិស៊ី ដោយការទុកចិត្ត និងក្ដីស្រលាញ់មិនងាករេ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេនខេស៊ី (ខេមបូឌា) ភីអិលស៊ី ត្រូវបានបង្កើតឡើង ក្នុងខែមីនា ឆ្នាំ ២០១៤។ មកទល់បច្ចុប្បន្ននេះ តាមរយៈទំនុកចិត្ត ដ៏រឹងមាំ របស់អតិថិជន គ្រឹះស្ថាន បានឈរជើង ធ្វើប្រតិបត្តិការនៅប្រទេសកម្ពុជា ដោយមានអតិថិជនសរុប ១០,០៣០នាក់ និងសាខាប្រតិបត្តិការ ចំនួន ២០សាខា។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេនខេស៊ី (ខេមបូឌា) ភីអិលស៊ី បានរួមចំណែក ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងស្រុក តាមរយៈការធ្វើប្រតិបត្តិការ លើវិស័យមីក្រូហិរញ្ញវត្ថុ ជាអាទិភាពចម្បង ដោយមានការផ្ដល់សេវាកម្មកម្ចីផ្សេងៗ ដូចជា កម្ចីអាជីវកម្ម កម្ចីទិញផ្ទះ កម្ចីកសិកម្ម និងកម្ចីគ្មានទ្រព្យធានា។ល។

គ្រឹះស្ថាន នឹងបន្តអភិវឌ្ឍនខ្លួន ដើម្បីភាពរីកចម្រើនរួមគ្នា ជាមួយអតិថិជន ក្រោមពាក្យស្លោក « ប៊ីអេនខេស៊ី ជាដៃគូអាជីវកម្មល្អបំផុតរបស់អ្នក » ។ បុគ្គលិកយើង ទាំងអស់ នឹងប្រឹងប្រែងឱ្យអស់ពីសមត្ថភាព ក្នុងការក្លាយខ្លួនជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលផ្ដល់សេវាហិរញ្ញវត្ថុប្រកបដោយ ភាពច្នៃប្រឌិត បែបឌីជីថល និងផ្ដោតសំខាន់ លើអតិថិជន ជាចម្បង ស្របតាមយុគសម័យឌីជីថល។

លើសពីនេះ ទៅទៀត គ្រឹះស្ថាន បាននិងកំពុងចូលរួមចំណែក ក្នុងសកម្មភាពសង្គមផ្សេងៗ តាមរយៈកាតព្វកិច្ច ទទួលខុសត្រូវសង្គម របស់សាជីវកម្មមួយ។ បុគ្គលិក គ្រប់ជាន់ថ្នាក់ នឹងអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាម គោលការណ៍ និងសេចក្ដីណែនាំ របស់ធនាគារជាតិនៃកម្ពុជា តួយ៉ាងរក្សាឱ្យបាននូវតម្លាភាព សីលធម៌របស់បុគ្គលិក ទំនួលខុសត្រូវ និងការគ្រប់គ្រង ប្រកបដោយក្រមសីលធម៌ ក្នុងន័យព្យាយាមធ្វើយ៉ាងណាឱ្យ ប៊ីអេនខេស៊ី ក្លាយជាគ្រឹះស្ថាន ដែលឈរលើគ្រឹះនៃភាពស្មោះត្រង់ និងជំនឿទុកចិត្ត។

ខ្ញុំសូមជូនពរ អតិថិជនរបស់គ្រឹះស្ថាន ប៊ីអេនខេស៊ី ទាំងអស់ ប្រកបដោយ សុខភាពល្អ សុភមង្គល និងការរីកចម្រើនជានិច្ចនិរន្តរ៍។ សូមអរគុណ!

ពីខ្ញុំអគ្គនាយកប្រតិបត្តិ



**លោក LEE SIHYUN**
**អគ្គនាយកប្រតិបត្តិ**

# ប្រតិបត្តិការ
# របស់យើង



# សាខា

១

## ទីស្នាក់ការកណ្តាល

អាគារ ប៊ី-រ៉ាយ ជាន់ផ្ទាល់ដី-ជាន់ទី៤ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ៖ ០២៣ ២១៣ ៩០០

២

## សាខាស្រុកអង្គស្នួល

ភូមិចុងបង្គោល ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល
ទូរស័ព្ទ៖ ០២៣ ៧២៩ ៧១១

៣

## សាខាស្រុកកណ្តាលស្ទឹង

ភូមិសៀមរាប ឃុំសៀមរាប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល
ទូរស័ព្ទ៖ ០២៤ ៩០០ ១៣៥

៤

## សាខាស្រុកខ្សាច់កណ្តាល

ភូមិព្រែកតាមាក់ ឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល
ទូរស័ព្ទ៖ ០២៤ ៩០០ ១៣១

៥

## សាខាក្រុងច្បារមន

ភូមិបុរីកម្មករ សង្កាត់រកាធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ
ទូរស័ព្ទ៖ ០២៥ ២១០ ២២៩

៦

## សាខាក្រុងឧដុង្គម៉ែជ័យ

ភូមិស្រះកែវ សង្កាត់វាំងចាស់ ក្រុងឧដុង្គម៉ែជ័យ ខេត្តកំពង់ស្ពឺ
ទូរស័ព្ទ៖ ០២៥ ២១៨ ២៨២

៧

## សាខាស្រុកបរសេដ្ឋ

ភូមិផ្សារស្លាបលែង ឃុំស្វាយរំពារ ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ
ទូរស័ព្ទ៖ ០២៥ ៩០០ ១១០

៨

## សាខាស្រុកថ្ពង

ភូមិមនោរម្យ ឃុំមនោរម្យ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ
ទូរស័ព្ទ៖ ០២៥ ៩០០ ១១៩

៩

## សាខាស្រុកជើងព្រៃ

ភូមិប៉ាណា ឃុំសូទិព្វ ស្រុកជើងព្រៃ ខេត្តកំពង់ចាម
ទូរស័ព្ទ៖ ០៤២ ៩០០ ១១០

១០

## សាខាស្រុកត្រាំកក់

ភូមិអង្គតាសោម ឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ
ទូរស័ព្ទ៖ ០៣២ ២១៥ ២១៥

១១

## សាខាស្រុកបាទី

ភូមិព្រហែក ឃុំសូរភី ស្រុកបាទី ខេត្តតាកែវ
ទូរស័ព្ទ៖ ០៣២ ៩០០ ១១៨

១២

## សាខាស្រុកសំរោង

ភូមិព្រៃទទឹង ឃុំសំរោង ស្រុកសំរោង ខេត្តតាកែវ
ទូរស័ព្ទ៖ ០៣២ ៩០០ ១១៩

១៣

## សាខាស្រុកឈូក

ភូមិឈើទាល ឃុំឈូក ស្រុកឈូក ខេត្តកំពត
ទូរស័ព្ទ៖ ០៣៣ ៩០០ ១៣៥

១៤

## សាខាក្រុងកំពត

ភូមិស្វាយធំ សង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត
ទូរស័ព្ទ៖ ០៣៣ ៩០០ ១១០

១៥

## សាខាក្រុងសៀមរាប

ភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប
ទូរស័ព្ទ៖ ០៦៣ ៧៥៦ ៧២២

១៦

## សាខាក្រុងបាត់ដំបង

ភូមិកម្មករ សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង
ទូរស័ព្ទ៖ ០៥៣ ៩៥២ ៩៥២

១៧

## សាខាក្រុងសេរីសោភ័ណ

ភូមិ៣ សង្កាត់ព្រះពន្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ
ទូរស័ព្ទ៖ ០៥៤ ៩០០ ១១២

១៨

## សាខាក្រុងប៉ោយប៉ែត

ភូមិប៉ាលិលេយ្យ២ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ
ទូរស័ព្ទ៖ ០៥៤ ៩០០ ១១០

១៩

## សាខាស្រុកពាមរក៍

ភូមិព្រែករាំង ឃុំពន្លិចប្រសាទ ស្រុកពាមរក៍ ខេត្តព្រៃវែង
ទូរស័ព្ទ៖ ០៤៣ ៩០០ ១១៨

២០

## សាខាស្រុកស្វាយអន្ទរ

ភូមិស្វាយអន្ទរទី១ ឃុំស្វាយអន្ទរ ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង
ទូរស័ព្ទ៖ ០៤៣ ៩០០ ១១៩

# ផលិតផល

## ប្រាក់កម្ចីធានា

### ឥណទានអាជីវកម្ម

$ 500 ~

ឥណទានអាជីវកម្ម ត្រូវបានរចនាឡើង សម្រាប់អតិថិជន ដែលត្រូវការដើមទុន សម្រាប់បង្កើត ឬពង្រីកអាជីវកម្មថ្មី ដើម្បីទទួលបាន ប្រាក់ចំណេញ កាន់តែច្រើន។ ទំហំកម្ចី ផ្តល់ជូនតាមតម្រូវការ របស់អតិថិជន និងមានរយៈពេល កម្ចីរហូតដល់ 72 ខែ។

### ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន

$ 15,000

ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន ត្រូវបានផ្តល់ជូន ដល់ អតិថិជន ដែលអាចមានលទ្ធភាព ទិញសម្ភារៈ សម្រាប់ គ្រួសារ ឬប្រើប្រាស់ផ្ទាល់ខ្លួន។ ទំហំឥណទាន ផ្តល់ជូនដល់ USD 15,000 ឬសមមូលនឹង ប្រាក់រៀលខ្មែរ និងមានរយៈពេលរហូតដល់ 60 ខែ។

### ឥណទានរថយន្ត

$ 30,000

ឥណទានរថយន្ត ត្រូវបានរចនាឡើង សម្រាប់ អតិថិជន ដែលមានបំណង ទិញយានយន្ត (រថយន្តធន់តូច / រថយន្តដឹកទំនិញ) សម្រាប់ប្រើប្រាស់ ក្នុងតម្រូវការអាជីវកម្ម និងគ្រួសារ។ ទំហំឥណទាន ផ្តល់ជូនដល់ USD 30,000 ឬ សមមូលនឹង ប្រាក់រៀលខ្មែរ និងមានរយៈពេល រហូតដល់ 72 ខែ។

### ឥណទានសម្រាប់កែលម្អគេហដ្ឋាន

$ 15,000

ឥណទានកែលម្អគេហដ្ឋាន គឺពិសេស សម្រាប់អតិថិជន ដែលត្រូវការដើមទុន សម្រាប់កែលម្អគេហដ្ឋាន / អគារទំហំតូច ឬមធ្យមដែលមានស្រាប់។ ទំហំឥណទាន ផ្តល់ជូនដល់ USD 15,000 ឬសមមូលនឹង ប្រាក់រៀលខ្មែរ និងមានរយៈពេលរហូតដល់ 60 ខែ។

### ឥណទានគេហដ្ឋាន

$ 500 ~

ឥណទានគេហដ្ឋាន ត្រូវបានផ្តល់ជូន ដល់អតិថិជន ដែលមានត្រូវការ ដើម្បីទិញដី សាងសង់ផ្ទះក្នុងក្តីស្រមៃ ខុនដូ និងអាផាតមិន ជាដើម។ ទំហំឥណទាន និងរយៈពេល គឺមានភាពបត់បែន ដោយអាស្រ័យលើ ការចរចា និង ស្ថានភាព របស់អតិជនផ្ទាល់។

### ឥណទានកសិកម្ម

$ 30,000

ឥណទានកសិកម្ម ផ្តល់ជូនដល់ អតិថិជន ដែលមានបំណងចង់ធ្វើ ឬពង្រីក សកម្មភាពកសិកម្ម បង្កើតប្រាក់ចំណូលពីកសិកម្ម ដូចជា ចិញ្ចឹមសត្វ ដាំបន្លែ នេសាទជាដើម។ ទំហំឥណទាន ផ្តល់ជូនដល់ USD 30,000 ឬសមមូលនឹងប្រាក់រៀលខ្មែរ និងមានរយៈពេល រហូតដល់ 72 ខែ។

### ឥណទានសូឡា

$ 30,000

ឥណទានសូឡា ជាកម្ចីបុគ្គល / អាជីវកម្ម ត្រូវបានរចនាឡើង សម្រាប់អតិថិជន ដែលត្រូវការដើមទុន ដើម្បីដំឡើងបន្ទះស្រូបពន្លឺព្រះអាទិត្យ នៅកន្លែងអាជីវកម្ម ឬគេហដ្ឋាន។ ទំហំឥណទាន ផ្តល់ជូនដល់ USD 30,000 ឬសមមូលនឹងប្រាក់រៀលខ្មែរ និងមានរយៈពេលរហូតដល់ 72 ខែ។

# ប្រាក់កម្ចីគ្មានការធានា

### ឥណទានទិញសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃ

$ 10,000

ឥណទានសម្រាប់ទិញសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួន គឺជាឥណទានដែលមិនតម្រូវអោយមាន ទ្រព្យធានា។ អតិថិជន ប្រើឥណទាននេះ ដើម្បីទិញ ឧបករណ៍អេឡិចត្រូនិក ចាំបាច់ប្រចាំថ្ងៃ ដូចជា ទូរស័ព្ទទំនើប កុំព្យូទ័រយួរដៃ ទូទឹកកក។ល។ ទំហំឥណទានផ្តល់ជូនដល់ USD 10,000 ឬសមមូលនឹង ប្រាក់រៀលខ្មែរ និងមានរយៈពេលរហូតដល់ 36 ខែ។

### ឥណទានសូឡា

$ 6,000

ឥណទានសូឡា ជាកម្ចីបុគ្គល / អាជីវកម្ម ត្រូវបានរចនាឡើង សម្រាប់អតិថិជន ដែលត្រូវការដើមទុន ដើម្បីដំឡើងបន្ទះស្រូបពន្លឺព្រះអាទិត្យ នៅកន្លែងអាជីវកម្ម ឬគេហដ្ឋាន។ ទំហំឥណទាន ផ្តល់ជូនដល់ USD 6,000 ឬសមមូលនឹងប្រាក់រៀលខ្មែរ និងមានរយៈពេលរហូតដល់ 24 ខែ។

# អតិថិជន ប៊ីអេនខេស៊ី

## ចំណាប់អារម្មណ៍អតិថិជន

### (សើ ឆាន / សាខាស្រុកឈ្លូក)

ក្នុងពេលកំពុងស្វែងរកឥណទាន ដើម្បីពង្រីកអាជីវកម្ម មិត្តភ័ក្តរបស់ខ្ញុំ បានណែនាំខ្ញុំពីសេវាកម្មកម្ចីនៅ BNKC ។ ក្រោយពេលទទួលបានការពន្យល់ យ៉ាងក្បោះក្បាយពីបុគ្គលិក អំពីសេវាកម្ម ប្រាក់កម្ចី ខ្ញុំក៏ សម្រេចចិត្ត ប្រើប្រាស់សេវាកម្មរបស់ BNKC ។ ក្រោយទទួលបានប្រាក់កម្ចី ខ្ញុំបានពង្រីកអាជីវកម្ម លក់ចាប់ហួយរបស់ខ្ញុំ ដោយបានបន្ថែមផលិតផលជាច្រើនមុខ ដើម្បី អាចបំពេញតម្រូវការ របស់អតិថិជន បានទិញម៉ាស៊ីនកិនស្រូវ និងទិញជ្រូកចញ្ចឹមបន្ថែម ធ្វើអោយប្រាក់ចំណូលកើនឡើង មានលទ្ធភាពកែលម្អផ្ទះ ហើយមានជីវភាព កាន់តែប្រសើរឡើង មួយកម្រិត។ ទៅថ្ងៃអនាគតប្រសិនបើមាន តម្រូវការកម្ចីបន្ថែមទៀត ខ្ញុំនឹងជ្រើសយកសេវាកម្មរបស់ BNKC ក៏ដូចជាណែនាំពីសេវាកម្មនេះទៅកាន់ មិត្តភក្តិបងប្អូន។



### (អ៊ឹម ចិន្តា / សាខាស្រុកថ្ពង)

នាងខ្ញុំ បានជ្រើសរើស ប្រើប្រាស់សេវាកម្ម កម្ចីខ្នាតតូច របស់ BNKC ក្រោយទទួលបានការផ្សព្វផ្សាយ ពីមន្ត្រីឥណទាន។ តាមរយៈការប្រើប្រាស់ សេវាកម្មកម្ចីនេះ ធ្វើអោយអាជីវកម្មរបស់ខ្ញុំ មានភាពល្អប្រសើរជាងមុន តូបកាត់សក់ ត្រូវបានធ្វើថ្មី មានអតិថិជនកាត់សក់កាន់តែច្រើន លើសពីនេះ ទៅទៀត ខ្ញុំបានបង្កើតមុខរបរថ្មីមួយទៀត គឺលក់សម្លៀកបំពាក់។ ខ្ញុំពេញចិត្ត ពីការពន្យល់ យ៉ាងយកចិត្តទុកដាក់ ពីសំណាក់មន្ត្រីឥណទាន ហើយម៉្យាងទៀត វាល្អណាស់ ដែលមានកម្មវិធីទូរសព្ទ ព្រោះងាយស្រួលក្នុងការពិនិត្យមើលកាលបរិច្ឆេទសងប្រាក់កម្ចី និងចំនួនទឹកសងប្រាក់។



### (ពៅ ចាន់ / សាខាស្រុកបាទី)

ខ្ញុំបានស្គាល់ មន្ត្រីឥណទាននៅ BNKC យូរណាស់មកហើយ។ គាត់រួសរាយរាក់ទាក់ សន្យាច្បាស់លាស់ និងស្មោះត្រង់ ម៉្យាងទៀត ដំណើរការឥណទាន មានភាពរហ័ស និងងាយស្រួល ក្នុងការបង់សងប្រាក់ ប្រចាំខែផង ខ្ញុំក៏ សម្រេចចិត្ត ប្រើប្រាស់ សេវាកម្មឥណទានរបស់ BNKC។ ការប្រកបអាជីវកម្មខ្ញុំពីមុន មានដើមទុនតិចតួច លក់ស្មើរមុខស្មើរក្រោយ ប៉ុន្តែ បន្ទាប់ពីប្រើប្រាស់ឥណទាននេះមក ខ្ញុំបានពង្រីកអាជីវកម្ម លក់នំប៉័ងដាក់សាច់ បានប្រសើរជាងមុន មានអតិថិជនច្រើនជាងមុន ធ្វើអោយជីវភាពបានប្រសើរមួយកម្រិត។ ខ្ញុំពេញចិត្ត សេវាកម្មនៅ BNKC សេវាកម្មល្អ អត្រាការប្រាក់ ក៏សមរម្យ ហើយខ្ញុំក៏បានណែនាំដល់បងប្អូនរបស់ខ្ញុំ អំពីសេវាកម្ម នៅទីនេះដែរ។



# កម្មវិធីទូរសព្ទដៃ

# BNKC Mobile App



## មុខងារ

- ស្នើសុំប្រាក់កម្ចីនិងការគ្រប់គ្រងកម្ចី
- សងប្រាក់កម្ចីតាមរយៈភ្នាក់ងារ WING ឬ True Money






- ប្រឹក្សាប្រាក់កម្ចី
- ស្វែងរកទីតាំងសាខា

## សេចក្តីណែនាំ

កម្មវិធីទូរសព្ទចល័ត « BNKC Mobile App » ដែលត្រូវបាន ដាក់ឱ្យដំណើរការ ក្នុងខែមិថុនា ឆ្នាំ២០២១ គឺជាការបង្ហាញ ពីប្រសិទ្ធភាព នៃការច្នៃប្រឌិត ឌីជីថល ដែលផ្តោតលើតម្រូវការរបស់អ្នកប្រើប្រាស់។ វាជាជំហានដំបូង ក្នុងការផ្លាស់ប្តូរ ទៅកាន់យុគ្គសម័យបច្ចេកវិទ្យា ដែលផ្តល់ភាពងាយស្រួយ និងសន្សំសំចៃ ពេលវេលា ជូនដល់អតិថិជន ដែលត្រូវការប្រើប្រាស់សេវាកម្មហិរញ្ញវត្ថុ របស់គ្រឹះស្ថាន។

« BNKC Mobile App » ជាកម្មវិធីទូរស័ព្ទដៃរបស់ MFI ដំបូងគេ ដែលត្រូវបានដាក់អោយដំណើរការ នៅក្នុងប្រទេសកម្ពុជា ដែលអាចកំណត់ នូវតម្រូវការ របស់អតិថិជន ហើយមុខងារ និងការរចនា មានលក្ខណៈសាមញ្ញ សមស្រប និងងាយស្រួល សម្រាប់អតិថិជនទាំង ពីរភេទ ក្នុងការចូលទៅប្រើប្រាស់។ លើសពីនេះ ទៅទៀត ជាមួយនឹងមុខងារ ដូចជា ការស្នើសុំប្រាក់កម្ចី និងការគ្រប់គ្រងកម្ចី ការសងប្រាក់កម្ចី តាមរយៈភ្នាក់ងារ WING ឬ True Money កាលវិភាគសងប្រាក់កម្ចី ការប្រឹក្សាប្រាក់កម្ចី ស្វែងរកទីតាំងសាខា ជួយអោយអតិថិជន ទទួលបានបទពិសោធន៍ ប្រើប្រាស់ហិរញ្ញវត្ថុ ដែលមានសុវត្ថិភាព និងទំនុកចិត្តខ្ពស់។

គិតត្រឹមខែធ្នូ ឆ្នាំ២០២៣ អតិថិជន ប្រហែល ៤៨,៦៨៦នាក់ បានទាញយក កម្មវិធី « BNKC Mobile App » ។ ការប្រឹក្សា ប្រាក់កម្ចី និងការស្នើសុំកម្ចី ត្រូវធ្វើឡើងយ៉ាងសកម្មនៅលើកម្មវិធីនេះ។ ប៊ីអេនខេសុី នឹងបន្តផ្តល់ នូវភាពច្នៃប្រឌិត ឌីជីថល ផ្នែកហិរញ្ញវត្ថុ ដោយឆ្លុះបញ្ចាំង ពីតម្រូវការ របស់អតិថិជន ដើម្បីជីវិតហិរញ្ញវត្ថុ ដ៏ឆ្លាតវៃរបស់អតិថិជន នាពេលអនាគត។

**៤,៤៣៨**

ចំនួនអតិថិជនស្នើសុំកម្ចីតាមទូរស័ព្ទសរុប៖

**៣២០**

ចំនួនអតិថិជនសកម្មសរុប៖

**$១,៤៣១,៤២៥**

ចំនួនទឹកប្រាក់សរុប៖

# ក្រុមការងារ របស់យើង



# រចនាសម្ព័ន្ធគ្រឹះស្ថាន



# គណៈគ្រប់គ្រងកំពូល



## លោក LEE SIHYUN

### អគ្គនាយកប្រតិបត្តិ

លោក LEE Sihyun បានឡើងតំណែងជា អគ្គនាយកប្រតិបត្តិ នៅខែមេសា ឆ្នាំ២០២៣។ លោកបាន បញ្ចប់ការសិក្សា ថ្នាក់បរិញ្ញាបត្រវិស្វកម្មប៉ូលីមែរ នៅសាកលវិទ្យាល័យជាតិភុក្យុង នៃសាធារណរដ្ឋកូរ៉េ នៅក្នុងឆ្នាំ១៩៩៨។ លោកមានបទពិសោធន៍ ជាច្រើនឆ្នាំ ទាក់ទងនឹងវិស័យហិរញ្ញវត្ថុ នៅសាធារណរដ្ឋកូរ៉េ។ លោកបាន បម្រើការងារ នៅធនាគារ Busan Parangsae Saving Bank អស់រយៈពេល ៤ឆ្នាំក្នុងតួនាទី ជាប្រធានគ្រប់គ្រងឥណទាន។ លោកបានចូលបម្រើការងារនៅ BNK Capital ក្នុងខែតុលា ឆ្នាំ២០១១ យោងទៅលើលទ្ធផលការងារ ដ៏ឆ្នើមជាច្រើន របស់លោកនៅ BNK Capital លោកត្រូវបានតែងតាំង អោយកាន់តំណែង ក្នុងផ្នែកគ្រប់គ្រង ជាច្រើនបន្តបន្ទាប់គ្នា ដូចជា គ្រប់គ្រងប្រឹក្សាយោបល់អតិថិជន គ្រប់គ្រងគម្រោងឥណទាន គ្រប់គ្រងត្រួតពិនិត្យឥណទាន និងគ្រប់គ្រងផ្នែកគ្រប់គ្រងហានិភ័យ។



## លោក JANG HYUNSEOK

### អគ្គនាយករង ទី១

លោក JANG HYUNSEOK បានចាប់ផ្តើមការងារនៅគ្រឹះស្ថាន នៅខែមករា ឆ្នាំ២០២៣។ លោកបាន បញ្ចប់ការសិក្សា ថ្នាក់បរិញ្ញាបត្រ ផ្នែកពាណិជ្ជកម្មអន្តរជាតិ នៅសកលវិទ្យាល័យ ដុងអានៅ ក្នុងឆ្នាំ២០០៦។ លោកមានបទពិសោធន៍ជាង ១០ឆ្នាំ ទាក់ទងនឹង វិស័យហិរញ្ញវត្ថុ នៅសាធារណរដ្ឋកូរ៉េ។ លោកបានបម្រើការងារ នៅធនាគារ Heung-Kook Saving Bank អស់រយៈពេល ៦ឆ្នាំ ក្នុងតួនាទី ជាសមាជិកក្នុងក្រុមគម្រោងហិរញ្ញវត្ថុ។ លោកបាន ចូលបម្រើការនៅ BNK Capital ក្នុងឆ្នាំ២០១៤ យោងទៅលើលទ្ធផលការងារ ដ៏ឆ្នើមជាច្រើន របស់លោក លោកត្រូវបានតែងតាំង អោយកាន់តំណែង ជាច្រើន បន្តបន្ទាប់គ្នា ដូចជា សមាជិក នៃក្រុមផែនការយុទ្ធសាស្ត្រ ប្រធានក្រុមគម្រោងហិរញ្ញវត្ថុ និងជាប្រធានក្រុម រៀបចំផែនការហិរញ្ញវត្ថុ។



# លោក PARK HYUNGMO

## អគ្គនាយករង ទី២

លោក PARK HYUNGMO បានឡើងតំណែងជាអគ្គនាយករង នៅខែមករា ឆ្នាំ២០២៣។ លោកបញ្ចប់ ការសិក្សា កំរិតបរិញ្ញាបត្រ ផ្នែកវិទ្យាសាស្ត្រ និងវិស្វកម្មកុំព្យូទ័ពីសាកលវិទ្យាល័យជាតិ Pusan នៃសាធារណរដ្ឋកូរ៉េ។ លោកបានចាប់ផ្តើម អាជីពការងារ នៅ BNK Capital នៅឆ្នាំ២០១២ ក្នុងមុខដំណែង ជាមន្ត្រី ផ្នែកព័ត៌មានវិទ្យា។ កំឡុងរយៈពេល ១០ឆ្នាំ គាត់បានចូលរួមគម្រោងផែនការ ការងារជាច្រើន ដូចជាគម្រោងអភិវឌ្ឍកម្មវិធីទូរសព្ទដៃ គម្រោងអភិវឌ្ឍ ប្រព័ន្ធធនាគារ ជាដើម។ លោក HYUNGMO ក៏ធ្លាប់បានចូលរួម ក្នុងគម្រោងសាជីវកម្មគ្រប់គ្រងដោយ SAMSUNG នៅវេទិកាហិរញ្ញវត្ថុអន្តរជាតិ Pusan នៅសាធារណរដ្ឋកូរ៉េ។ លោកមានជំនាញជាច្រើនដូចជា Java, PHP, Java Script, C, C++, HTML, XML និង Oracle ។ល។

# គណៈគ្រប់គ្រង





## កញ្ញា ពៅ សាឡឹម ប្រធាននាយកដ្ឋានផែនការ

កញ្ញា ពៅ សាឡឹម មានមុខតំណែងជា ប្រធាននាយកដ្ឋានផែនការ នៅក្នុងគ្រឹះស្ថាន។ កញ្ញាបាន ចូលបម្រើការងារនៅគ្រឹះស្ថាន នៅខែមករា ឆ្នាំ២០១៦ ជាជំនួយការអគ្គនាយកប្រតិបត្តិ។ កញ្ញា ក៏ធ្លាប់ចូលរួម ក្នុងគម្រោងសិក្សាស្រាវជ្រាវ និងវិភាគជាច្រើន លើផ្នែកអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ច នៅសាកលវិទ្យាល័យ ក្នុងសាធារណរដ្ឋកូរ៉េ មុនត្រឡប់មកប្រទេសកម្ពុជាវិញ។ កញ្ញា ពៅ សាឡឹម បានបញ្ចប់ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញរដ្ឋបាលសាធារណៈ នៅឆ្នាំ២០១៤ និងបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ ចំនួនពីរ ផ្នែកសេដ្ឋកិច្ច និង ផ្នែករដ្ឋបាលសាធារណៈ នៅសាកលវិទ្យាល័យស្ត្រី Ewha ក្នុងសាធារណរដ្ឋកូរ៉េ នៅឆ្នាំ២០១១។

---



## លោក អ៊ុន រតនៈ ប្រធាននាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាល

លោក អ៊ុន រតនៈ មានមុខតំណែងជា ប្រធាននាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាល។ លោកបាន ចូលបម្រើការងារនៅគ្រឹះស្ថាន នៅខែ មិថុនា ឆ្នាំ២០១៦។ មុនការចាប់អាជីពនៅគ្រឹះស្ថាន ប៊ីអេនខេស៊ី លោកធ្លាប់ធ្វើជា ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងជាជំនួយការ ប្រធានគម្រោង នៅក្រុមហ៊ុនសាងសង់ អស់រយៈពេល ៣ឆ្នាំ។ លោក ក៏ធ្លាប់ជានាយកគ្រប់គ្រងសាលារៀន នៃអង្គការ ICMS Mission Society ដែលមានមូលដ្ឋាននៅប្រទេសថៃ រយៈពេល ១ឆ្នាំ។ លោក អ៊ុន រតនៈ បានបញ្ចប់ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញគ្រប់គ្រងធុរៈកិច្ច ពីសកលវិទ្យាល័យ បៀលប្រាយ នៅក្នុងខែមីនា ឆ្នាំ២០១៥។ ក្នុងឆ្នាំ២០១២ លោកបានបញ្ចប់ ថ្នាក់បរិញ្ញាបត្រ ចំនួនពីរ ក្នុងពេលតែមួយផងដែរ គឺទីមួយ ផ្នែកអន្តរវប្បធម៌ និងទីពីរ ផ្នែកអក្សរសាស្ត្រភាសាអង់គ្លេស ពីសាកលវិទ្យាល័យ KOSIN នៅទីក្រុងប៊ូសាន សាធារណរដ្ឋកូរ៉េ។ ក្រៅពីនេះ លោកបានសិក្សាវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសវិជ្ជាជីវៈ ស្តីពី អ្នកជំនាញគ្រប់គ្រងធនធានមនុស្ស ការប្រកាសអាករលើតម្លៃបន្ថែម តាមវិធីគិតអាករជំនួស (Reverse Charge) និងការប្រើប្រាស់ សេវាកម្មអេឡិចត្រូនិកពន្ធដារ អ្នកជំនាញគ្រប់គ្រងគំរោង ដំណើរការគ្រប់គ្រងលទ្ធផលការងារប្រកបដោយប្រសិទ្ធិភាព គោលការណ៍ និងអត្ថប្រយោជន៍ សមាជិក ប. ស. ស. លើប្រាក់សោធនិវត្តន៍ គ្រប់គ្រងការទូទាត់ប្រាក់ឈ្នួល និងទូទាត់ពន្ធដារកម្ពុជា ការគិតអត្ថប្រយោជន៍បុគ្គលិក ក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ យុទ្ធសាស្ត្រ រើសរៀប និងរក្សាបុគ្គលិក ធនធានមនុស្ស និងការប្រតិបត្តតាម ក្នុងវិស័យហិរញ្ញវត្ថុ ការគ្រប់គ្រងធនធានមនុស្ស សម្រាប់អ្នកគ្រប់គ្រងជួរមុខ ច្បាប់ស្តីពីការងារ និងការប្រតិបត្តិតាមច្បាប់ ការសរសេរគោលនយោបាយ និងគោលការណ៍គ្រប់គ្រងធនធានមនុស្ស ការគ្រប់គ្រងលទ្ធផលការងារនិយោជិក និងភាពជាអ្នកដឹកនាំ ការគ្រប់គ្រងរដ្ឋបាល និងគ្រប់គ្រងការិយាល័យ។ល។



## លោក ផេង ភ័ក្ត្រ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ

លោក ផេង ភ័ក្ត្រ បានចូលបម្រើការងារនៅគ្រឹះស្ថាន ក្នុងខែសីហា ឆ្នាំ២០១៩ មុខតំណែងជាប្រធាននាយកដ្ឋានហិរញ្ញវត្ថុ។ លោកមានបទពិសោធន៍ការងារ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ រយៈពេលលើស ១៨ឆ្នាំ។ មុនចាប់អាជីពការងារ ជាមួយគ្រឹះស្ថាន ប៊ីអេនខេស៊ី លោកធ្លាប់ធ្វើការ នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទទួលប្រាក់បញ្ញើ និងក្រុមហ៊ុនអន្តរជាតិ ក្នុងមុខតំណែង ជាច្រើនដូចជាសវនករផ្ទៃក្នុង គណនេយ្យករជាន់ខ្ពស់គណនេយ្យករគ្រប់គ្រងជាន់ខ្ពស់ ប្រធានត្រួតពិនិត្យហិរញ្ញវត្ថុ ប្រធានវិភាគអាជីវកម្ម ប្រធានរៀបចំផែនការថវិកា ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងរដ្ឋបាល ហើយលោក ក៏មានបទពិសោធន៍ ក្នុងការប្តូរប្រព័ន្ធធនាគារស្នូល ការធ្វើឲ្យកាន់តែប្រសើរ នូវប្រព័ន្ធការងារ និងជាគ្រូបង្រៀននៅសាកលវិទ្យាល័យ រយៈពេល ប្រាំមួយឆ្នាំ មុខវិជ្ជាគណនេយ្យ និងសវនកម្ម ផងដែរ។ លោកបានបញ្ចប់ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញគ្រប់គ្រងហិរញ្ញវត្ថុ ពីសកលវិទ្យាល័យ នីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច នៅក្នុងឆ្នាំ២០១១ និងបញ្ចប់ថ្នាក់បរិញ្ញបត្រហិរញ្ញវត្ថុ និងគណនេយ្យ ព្រមទាំង ថ្នាក់បរិញ្ញបត្រ អក្សរសាស្រ្តភាសាអង់គ្លេស ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង សាកលវិទ្យាល័យន័រតុន និងកំពុងបន្តការសិក្សាជំនាញគណនេយ្យករអាជីព។ ក្រៅពីនេះ លោកបានសិក្សា វគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសវិជ្ជាជីវៈ ស្តីពីការវិភាគសូចនាករ ប្រតិបត្តិហិរញ្ញវត្ថុ ការគ្រប់គ្រងទ្រព្យសកម្ម និងបំណុល ការគ្រប់គ្រងហានិភ័យ របាយការណ៍តុល្យការ ការបង្ហាញហានិភ័យឥណទាន ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិកម្ពុជា និងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ប្រព័ន្ធពន្ធដារកម្ពុជា ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ការគ្រប់គ្រងហានិភ័យ កម្មវិធីអភិវឌ្ឍអ្នកគ្រប់គ្រង ភាពជាអ្នកដឹកនាំ និងការលើកទឹកចិត្ត។ល។

---



## លោក ពៅ ច័ន្ទមិថុនា ប្រធាននាយកដ្ឋានវិភាគឥណទាន

លោក ពៅ ច័ន្ទមិថុនា មានមុខតំណែងជា ប្រធាននាយកដ្ឋានវិភាគឥណទាន។ លោកបានចូលបម្រើការងារក្នុងគ្រឹះស្ថាន នៅខែមិថុនា ឆ្នាំ២០២០។ មុនលោកចាប់អាជីពនៅគ្រឹះស្ថាន ប៊ីអេនខេស៊ី លោកធ្លាប់ បម្រើការងារ នៅក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុជាច្រើនមុខតំណែង ដូចជាប្រធានគ្រប់គ្រងប្រាក់កម្ចី ប្រធានភ្នាក់ងារឥណទាន នៅតាមបណ្តាធនាគារ ដ៏ឈានមុខ មួយចំនួន នៅប្រទេសកម្ពុជា។ លោកមានបទពិសោធន៍ និងចំណេះដឹង ខាងវិស័យហិរញ្ញវត្ថុ អស់រយៈពេលជាង ១០ឆ្នាំ។ លោក ពៅ ច័ន្ទមិថុនា បានបញ្ចប់ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញគ្រប់គ្រងពាណិជ្ជកម្ម ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង នៅក្នុងខែសីហា ឆ្នាំ២០១៥។ នៅក្នុងឆ្នាំ២០០៩ លោកបានបញ្ចប់ថ្នាក់បរិញ្ញបត្រ ជំនាញធនាគារ និងហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង។ នៅឆ្នាំ២០០៦ លោកបានបញ្ចប់ថ្នាក់ប្រកាសនីយបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងធនាគារ នៅមណ្ឌលសិក្សាបច្ចេកទេសធនាគារ។



## លោក ស៊ិន សុខនាង ប្រធាននាយកដ្ឋានឥណទាន

លោក ស៊ិន សុខនាង បានចាប់ផ្តើម ចូលបម្រើការងារនៅគ្រឹះស្ថាន នៅក្នុងខែធ្នូ ឆ្នាំ២០២២។ លោកមានបទពិសោធន៍ជាង ១៥ឆ្នាំ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ។ លោកធ្លាប់ជាមន្ត្រីឥណទាន មន្ត្រីឥណទានជាន់ខ្ពស់ ប្រធានតំបន់ នាយកសាខា នាយកភូមិភាគ និងនាយករងនាយកដ្ឋានគ្រប់គ្រងសាខា ជាមួយ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មួយកន្លែង នៅក្នុងប្រទេសកម្ពុជា។ លោក ស៊ិន សុខនាង បានបញ្ចប់ថ្នាក់ អនុបណ្ឌិត ផ្នែកហិរញ្ញវត្ថុ នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង នៅឆ្នាំ២០១២ និងបរិញ្ញាបត្រកសិកម្ម នៅសាកលវិទ្យាល័យ វេទមហាឫស្សី ខេត្តព្រៃវែង នៅឆ្នាំ២០០៤។ លោក ក៏បានចូលរួម វគ្គបណ្តុះបណ្តាល ផ្សេងៗទៀត ដូចជា ការអភិវឌ្ឍខ្លួនជាអ្នកដឹកនាំ គ្រូបង្គោល ការការពារ គ្រប់គ្រងឥណទានយឺតយ៉ាវ និងការនិយាយជាសាធារណៈ ជាដើម។



## លោក ហ៊ាប ចំរើន ប្រធាននាយកដ្ឋានដោះស្រាយបំណុល

លោក ហ៊ាប ចំរើន បានចាប់ផ្តើម ចូលបម្រើការងារនៅគ្រឹះស្ថាន នៅក្នុងខែមិថុនា ឆ្នាំ២០២៣។ លោកមានបទពិសោធន៍ជាង ១0ឆ្នាំ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ។ លោកធ្លាប់ជាមន្ត្រីឥណទាន មន្ត្រីឥណទានជាន់ខ្ពស់ មន្ត្រីស្តារបំណុលជាន់ខ្ពស់ អនុប្រធានសាខា និងប្រធានសាខា ជាមួយ គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ មួយកន្លែង នៅក្នុងប្រទេសកម្ពុជា។ លោក ហ៊ាប ចំរើន បានបញ្ចប់ ថ្នាក់បរិញ្ញាបត្រផ្នែក គណនេយ្យ នៅសាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ ខេត្តព្រៃវែង នៅឆ្នាំ២០១៦។ លោក ក៏បានចូលរួម វគ្គបណ្តុះបណ្តាលផ្សេងៗទៀត ដូចជា ការអភិវឌ្ឍខ្លួនជាអ្នកដឹកនាំ គ្រូបង្គោល ការការពារ និងគ្រប់គ្រងឥណទានយឺតយ៉ាវ និងការនិយាយជាសាធារណៈ ជាដើម។



## លោក ជា វណ្ណារិទ្ធ ជំនួយការជាន់ខ្ពស់ នាយកដ្ឋានគ្រប់គ្រងហានិភ័យ

លោក ជា វណ្ណារិទ្ធ ជំនួយការជាន់ខ្ពស់ នាយកដ្ឋានគ្រប់គ្រងហានិភ័យ លោកបានចូលបម្រើការងារនៅគ្រឹះស្ថាន នៅក្នុងខែតុលា ឆ្នាំ២០២៣។ លោកមានបទពិសោធន៍ជិត ១0ឆ្នាំ ក្នុងវិស័យហិរញ្ញវត្ថុ។ មុនពេលចាប់ផ្តើម ការងារជាមួយ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេនខេស៊ី លោកធ្លាប់បាន បម្រើការងារក្នុងតួនាទី មន្ត្រីឥណទាន មន្ត្រីគ្រប់គ្រងហានិភ័យឥណទាន និងមន្ត្រីគ្រប់គ្រងហានិភ័យ ប្រតិបត្តិការជាន់ខ្ពស់ ហើយលោក ក៏ធ្លាប់ជាសមាជិក ក្រុមគ្រូបង្គោលផងដែរ។ លោក ជា វណ្ណារិទ្ធ បានបញ្ចប់ ថ្នាក់បរិញ្ញាបត្រ ជំនាញគណិតវិទ្យា ក្នុងឆ្នាំ២០១៥ នៅសាកលវិទ្យាល័យស្វាយរៀង ខេត្តស្វាយរៀង។ លោក ក៏បានចូលរួម វគ្គបណ្តុះបណ្តាលផ្សេងៗ ជាច្រើនទៀត ដូចជា ការគ្រប់គ្រងហានិភ័យ ក្នុងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ការគ្រប់គ្រងហានិភ័យប្រតិបត្តិការ ការវាយតម្លៃឥណទាន អាជីវកម្មខ្នាតតូច និងមធ្យម និងវគ្គសិក្សាជំនាញគ្រូបង្គោល។



## លោក អាន សុខខាក់ ប្រធាននាយកដ្ឋានព័ត៌មានវិទ្យា

លោក អាន សុខខាក់ បានចូលបម្រើការងារនៅគ្រឹះស្ថាន នៅខែមេសា ឆ្នាំ២០១៥។ មុនចូលបម្រើការ នៅគ្រឹះស្ថាន លោកធ្លាប់ជា មន្ត្រីគ្រប់គ្រង Database នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយ រយៈពេល ២ឆ្នាំ និងជាអ្នកអភិវឌ្ឍន កម្មវិធីកុំព្យូទ័រ ក្នុងក្រុមហ៊ុនមួយ រយៈពេល ២ឆ្នាំ។ លោកក៏ធ្លាប់ជាបុគ្គលិក ផ្នែកសម្របសម្រួលព័ត៌មានវិទ្យា នៅសាលាអន្តរជាតិមួយ រយៈពេល ១ឆ្នាំ និងជាគ្រូបង្រៀនអភិវឌ្ឍន៍ កម្មវិធីកុំព្យូទ័រផងដែរ។ លោកបានបញ្ចប់ ការសិក្សាថ្នាក់បរិញ្ញាបត្រជំនាញវិស្វកម្ម និងបច្ចេកទេសកុំព្យូទ័រ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្នុងឆ្នាំ២០០៩។ លោកបានចូលរួម វគ្គបណ្តុះបណ្តាល ជំនាញបច្ចេកវិទ្យា ជាច្រើនផ្នែក ដូចជា C-Programming, C++, Java, C#, VB.net, PHP, MySQL, SQL Server, Database Management System និង IT Project Management ។



## កញ្ញា សៀ ណៃឡេង ប្រធាននាយកដ្ឋានប្រតិបត្តិតាម

កញ្ញា សៀ ណៃឡេង មានមុខដំណែងជា ប្រធាននាយកដ្ឋានប្រតិបត្តិតាម។ កញ្ញាបានចូលបម្រើការងារនៅគ្រឹះស្ថាន នៅខែមករា ឆ្នាំ២០១៩។ មុនពេលចាប់ផ្តើមអាជីពនៅគ្រឹះស្ថាន កញ្ញាធ្លាប់បម្រើការងារ ជាជំនួយការមេធាវី និងជាមន្ត្រីប្រតិបត្តិតាម នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយ។ កញ្ញា ក៏ធ្លាប់ជា អ្នកប្រឹក្សា ផ្នែកច្បាប់ ស្រាវជ្រាវផ្នែកច្បាប់។ កញ្ញា ត្រូវបានទទួលស្គាល់ជាផ្លូវការពីធនាគារជាតិនៃកម្ពុជា និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ក្នុងមុខងារជា មន្ត្រីប្រតិបត្តិតាម។ កញ្ញា សៀ ណៃឡេង បានបញ្ចប់ការសិក្សា ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំ២០១៧ និងបានបញ្ចប់ ថ្នាក់ភាសារអង់គ្លេសទូទៅពីសាកលវិទ្យាល័យបញ្ញាស្រ្តកម្ពុជា ផងដែរ។ ក្រៅពីនេះ កញ្ញាបានបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញ Regulatory Compliance និង Anti-Money Laundering នៅវិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ ព្រមទាំងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា។ល។



## លោក រឿន រិទ្ធា ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង

លោក រឿន រិទ្ធា បានចូលបម្រើការងារនៅគ្រឹះស្ថាន នៅខែឧសភា ឆ្នាំ២០១៩។ លោកចាប់ផ្តើមអាជីពជា សវនករផ្ទៃក្នុង នៅវិស័យធនាគារ និងហិរញ្ញវត្ថុ អស់រយៈពេល ជាង ១៣ឆ្នាំ។ មុនបម្រើការងារ នៅគ្រឹះស្ថាន លោកធ្លាប់ជា សវនករផ្ទៃក្នុង នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុសីលានិធិ រយៈពេល ៤ឆ្នាំ និងសវនករផ្ទៃក្នុងជាន់ខ្ពស់ នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី រយៈពេល ៥ឆ្នាំ។ លោកបានបញ្ចប់ ការសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ នៅសាកលវិទ្យាល័យន័រតុន ក្នុងឆ្នាំ២០០៩ និងកំពុងបន្តការសិក្សាថ្នាក់អនុបណ្ឌិត ជំនាញ នីតិឯកជន នៅពុទ្ធិកសាកលវិទ្យាល័យ ព្រះសីហមុនីរាជា។ ដើម្បីបំពេញបន្ថែម នូវចំណេះដឹង ផ្នែកសវនកម្ម លោកបានចូលរួមវគ្គសិក្សាខ្លី ជាច្រើន ដូចជា ការត្រួតពិនិត្យផ្ទៃក្នុង និងការការពារហានិភ័យ នៃការក្លែងបន្លំច្បាប់ពន្ធដារកម្ពុជា ការគ្រប់គ្រងសវនកម្មផ្ទៃក្នុង ច្បាប់កិច្ចសន្យា និងកិច្ចព្រមព្រៀងប្រាក់កម្ចី ក្នុងប្រតិបត្តិការហិរញ្ញវត្ថុ និងមូលដ្ឋានគ្រឹះនៃសវនកម្មផ្ទៃក្នុង និងទទួលបានវិញ្ញាបនបត្រថ្នាក់សវនកម្មជាន់ខ្ពស់ ទទួលស្គាល់ពី IFC នៅវិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ។

# សកម្មភាពការងារ
# របស់យើង



# ការអភិវឌ្ឍសមត្ថភាពបុគ្គលិក

## ការបណ្តុះបណ្តាលផ្ទៃក្នុង

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេនខេស៊ី (ខេមបូឌា) ភីអិលស៊ី តែងតែបង្កើត កម្មវិធីបណ្តុះបណ្តាលផ្ទៃក្នុង ជូនទៅដល់ បុគ្គលិកទាំងអស់ ដើម្បីជាការពង្រឹងចំណេះជំនាញ លើតួនាទីរបស់បុគ្គលិកម្នាក់ៗ អោយកាន់តែរីកចម្រើន ពីមួយឆ្នាំទៅមួយឆ្នាំ។ ការបណ្តុះបណ្តាលនេះ មិនត្រឹមតែ ធ្វើឡើងក្នុងគោលបំណង អោយបុគ្គលិកទទួលបាន ការយល់ដឹងកាន់តែច្បាស់ អំពីតួរនាទីការងារប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបណ្តុះ នូវការប្រកាន់យកផ្នត់គំនិត និងក្រមសីលធម៌ ការងារប្រកបដោយវិជ្ជាជីវៈ និងលើកកម្ពស់គុណតម្លៃ របស់បុគ្គលិកក្នុងវិស័យហិរញ្ញវត្ថុ។ ការបណ្តុះបណ្តាលផ្ទៃក្នុង ត្រូវបានធ្វើឡើងដោយ បុគ្គលិកថ្នាក់គ្រប់គ្រង ជាពិសេស បុគ្គលិកដែលមានសមត្ថភាពខ្ពស់ ឬបុគ្គលិកដែលមានជំនាញវិជ្ជាជីវៈ នៅក្នុងគ្រឹះស្ថាន ដើម្បីចែករំលែក ចំណេះដឹង និងការអនុវត្តន៍ អោយបានត្រឹមត្រូវ នូវគោលនយោបាយ និងគោលការណ៍ណែនាំ របស់គ្រឹះស្ថាន។

### នាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាល

#### ប្រធានបទ

១. ការតម្រង់ទិសបុគ្គលិក
២. ទប់ស្កាត់ការបៀតបៀនផ្លូវភេទនៅកន្លែងធ្វើការ
៣. ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង
៤. សកម្មភាពវិន័យ
៥. ការដោះស្រាយបញ្ហា (ឈ្នះ-ឈ្នះ)



ទប់ស្កាត់ការបៀតបៀនផ្លូវភេទនៅកន្លែងធ្វើការ

### នាយកដ្ឋានឥណទាន

#### ប្រធានបទ

១. តួនាទី និងការទទួលខុសត្រូវរបស់មន្ត្រីឥណទាន
២. តួនាទី និងទំនួលខុសត្រូវរបស់ប្រធានក្រុមមន្ត្រីឥណទាន
៣. បណ្តុះបណ្តាលស្មាតីសាមគ្គីរបស់សាខា


បណ្តុះបណ្តាលស្មាតីសាមគ្គីរបស់សាខា

### នាយកដ្ឋានដោះស្រាយបំណុល

#### ប្រធានបទ

១. យុទ្ធសាស្រ្តស្តារប្រាក់កម្ចី



ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង

## នាយកដ្ឋានហិរញ្ញវត្ថុ

### ប្រធានបទ

១. តួនាទី និងទំនួលខុសត្រូវរបស់អ្នកប្រធានបេឡាករ និងបេឡាករ

## នាយកដ្ឋានវាយតម្លៃឥណទាន

### ប្រធានបទ

១. តួនាទី និងការទទួលខុសត្រូវក្នុងការវាយតម្លៃឥណទាន


ការដោះស្រាយបញ្ហា (ឈ្នះ-ឈ្នះ)

## នាយកដ្ឋានគ្រប់គ្រងហានិភ័យ

### ប្រធានបទ

១. ការគ្រប់គ្រងហានិភ័យឥណទាន និងការគ្រប់គ្រងការក្លែងបន្លំ

## នាយកដ្ឋានប្រតិបត្តិតាម

### ប្រធានបទ

១. វគ្គបណ្តុះបណ្តាលប្រឆាំងការលាងលុយកខ្វក់
២. ការបណ្តុះបណ្តាលអនុលោមតាម


ប្រគល់វិញ្ញាបនបត្រជូនបុគ្គលិក


បុគ្គលិកបញ្ចប់ការបណ្តុះបណ្តាលដោយភាពជោគជ័យ

# វគ្គបណ្តុះបណ្តាលខាងក្រៅ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេនខេស៊ី (ខេមបូឌា) ភីអិលស៊ី បានធ្វើការវិនិយោគ ទៅលើធនធានមនុស្ស ជាចំបង ដោយរៀបចំបញ្ជូនបុគ្គលិករបស់ខ្លួន អោយចូលរួម វគ្គបណ្តុះបណ្តាល នៅឯស្ថាប័នខាងក្រៅ និងសិក្ខាសាលា ដែលរៀបចំឡើងដោយធនាគារជាតិនៃកម្ពុជា សមាគមន៍គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៃកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ ការិយាល័យឥណទានកម្ពុជា (CBC) និងក្រសួងពាក់ព័ន្ធផ្សេងទៀត ដូចជា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងពាណិជ្ជកម្ម ជាដើម។ ការបណ្តុះបណ្តាល ខាងក្រៅគ្រឹះស្ថានធ្វើឡើង ក្នុងគោលបំណង ពង្រឹងសមត្ថិភាព របស់បុគ្គលិក អោយមានចំណេះដឹង កាន់តែទូលំទូលាយ ការអនុវត្តន៍ការងារ មានប្រសិទ្ធភាព និងអាចជួយ ការងារប្រតិបត្តិការ របស់គ្រឹះស្ថាន កាន់តែរីកចម្រើនទៅមុខ ឥតឈប់ឈរ ដោយអនុលោមតាម ច្បាប់ពាណិជ្ជកម្ម ស្តង់ដារគណនេយ្យអន្តរជាតិ ជាពិសេស បញ្ញត្តិ និងសេចក្តីប្រកាសទាំងឡាយ ដែលចេញដោយ ធនាគារជាតិនៃកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ។

## នាយកដ្ឋានផែនការ

### ប្រធានបទ

១. ភាសាកូរ៉េសម្រាប់ធុរកិច្ច

## នាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាល

### ប្រធានបទ

១. ដំណើរការគ្រប់គ្រងការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាព
២. ការគ្រប់គ្រងការអនុវត្តសាខាប្រកបដោយប្រសិទ្ធភាព ជាមួយនឹងនិរន្តរភាព សីលធម៌ និងវិជ្ជាជីវៈ
៣. ស្នាត់ជំនាញ ៥ កម្រិតនៃភាពជាអ្នកដឹកនាំ
៤. ការអភិវឌ្ឍសមត្ថភាពស្ថាប័នសម្រាប់នាយកប្រតិបត្តិនៃគ្រឹះស្ថានហិរញ្ញវត្ថុ
៥. ការគ្រប់គ្រងរដ្ឋបាលប្រកបដោយប្រសិទ្ធភាព
៦. បច្ចុប្បន្នភាពគោលនយោបាយ និងអត្ថប្រយោជន៍ NSSF

## នាយកដ្ឋានហិរញ្ញវត្ថុ

### ប្រធានបទ

១. របាយការណ៍ហិរញ្ញវត្ថុ និងការវិភាគអនុលោមតាម CIFRS សម្រាប់សហគ្រាសធុនតូច និងមធ្យម


ការគ្រប់គ្រងរដ្ឋបាលប្រកបដោយប្រសិទ្ធភាព


សន្និសីទមីក្រូហិរញ្ញវត្ថុប្រចាំឆ្នាំ



ការអភិវឌ្ឍយុទ្ធសាស្ត្រអាជីវកម្ម



ការវិភាគអនុលោមតាម CIFRS សម្រាប់សហគ្រាសធុនតូច និងមធ្យម



AWS Experiential Hands on Workshop Session

## នាយកដ្ឋានប្រតិបត្តិតាម

### ប្រធានបទ

១. បទប្បញ្ញត្តិអនុលោមភាព

## នាយកដ្ឋានឥណទាន

### ប្រធានបទ

១. ការអភិវឌ្ឍយុទ្ធសាស្ត្រអាជីវកម្ម
២. ការគ្រប់គ្រងការអនុវត្តសាខាប្រកបដោយប្រសិទ្ធភាព ជាមួយនឹងនិរន្តរភាព សីលធម៌ និងវិជ្ជាជីវៈ
២. សន្និសីទមីក្រូហិរញ្ញវត្ថុប្រចាំឆ្នាំ

## នាយកដ្ឋានព័ត៌មានវិទ្យា

### ប្រធានបទ

១. AWS Experiential Hands on Workshop Session
២. មុខងារសវនកម្ម ICT ជាក់ស្តែងសម្រាប់ស្ថាប័នហិរញ្ញវត្ថុ

## នាយកដ្ឋានសវនកម្មផ្ទៃក្នុង

### ប្រធានបទ

១. សវនកម្មប្រឆាំងការលាងលុយកខ្វក់ (AML)



មុខងារសវនកម្ម ICT ជាក់ស្តែងសម្រាប់ស្ថាប័នហិរញ្ញវត្ថុ

# គោលការណ៍ការពារអតិថិជន

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេនខេស៊ី (ខេមបូឌា) ភីអិលស៊ី បានយកចិត្តទុកដាក់ អនុវត្តន៍តាម គោលការណ៍គាំពារអតិថិជនរបស់ធនាគារជាតិ នៃកម្ពុជា និងប្រកាន់ខ្ជាប់ជានិច្ច នូវគោលគំនិត ទិសដៅមូលដ្ឋាន បីសំខាន់ (មនុស្ស ផែនដី និងប្រាក់ចំណេញ) ព្រមជាមួយគ្នានឹង ការគោរពចំពោះបរិស្ថាន សង្គម និងសហគមន៍ ដែលយើងរស់នៅ។ ដូច្នេះ គោលការណ៍ណែនាំទាំងប្រាំពីរ នៃការការពារអតិថិជន ដែលត្រូវអនុវត្តតាម យ៉ាងខ្ជាប់ខ្ជួន មានដូចជា៖



- ១ ការបង្កើត និងការផ្តត់ផ្គង់ផលិតផលសមស្រប
- ២ ការបង្ការបំណុលហួសកម្រិត
- ៣ តម្លាភាព
- ៤ ការកំណត់តម្លៃសមរម្យ
- ៥ ភាពស្មោះត្រង់ និងការគោរពអតិថិជន
- ៦ ការរក្សាព័ត៌មានសម្ងាត់របស់អតិថិជន
- ៧ យន្តការសម្រាប់ដោះស្រាយបណ្តឹងរបស់អតិថិជន



# ដំណើរទស្សនកិច្ចរបស់អគ្គនាយកក្រុមហ៊ុន

# BNK Financial Group

## ដំណើរទស្សនកិច្ចរបស់អគ្គនាយក ប្រចាំឆ្នាំ២០២៣




កាលពីថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២៣ ដែលជា ដំណើរទស្សនកិច្ចជាលើកដំបូង មកកាន់ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្នុងប្រទេសកម្ពុជា របស់លោកអគ្គនាយក ក្រុមហ៊ុន BNK Financial Group និងនាយកប្រតិបត្តិ នៃក្រុមហ៊ុន BNK Capital ដោយត្រូវបាន ទទួលស្វាគមន៍ដោយភាព ស្និទ្ធស្នាល និងកក់ក្ដៅ ពីសំណាក់បុគ្គលិក គ្រប់ជាន់ថ្នាក់ នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេនខេស៊ី (ខេមបូឌា) ភីអិលស៊ី ការិយាល័យកណ្ដាល រាជធានីភ្នំពេញ។

ក្នុងឱកាស ដ៏វិសេសវិសាលនេះ លោកអគ្គនាយក និងនាយកប្រតិបត្តិ បានបង្ហាញ នូវសេចក្ដីរីករាយ និងបានរំពឹងទុកខ្ពស់ចំពោះ ចក្រវិស័យហិរញ្ញវត្ថុ ក្នុងប្រទេសកម្ពុជា ហើយ ក៏មានក្ដីសង្ឃឹមយ៉ាង មុតមាំ អំពីស្ថានភាពវិជ្ជមាន ដែលនឹងមកដល់ នាពេលអនាគត ដ៏ខ្លីខាងមុខនេះ។ លើសពីនេះ ទៅទៀត លោកអគ្គនាយក និងនាយកប្រតិបត្តិ បានមានជំនួប ពិភាក្សាជាមួយ អគ្គទេសាភិបាលរង ធនាគារជាតិ នៃកម្ពុជា ឯកឧត្តម រ័ត្ន សុវណ្ណនរៈ លើប្រធានបទ គោលនយោបាយ និងទិសដៅនៃវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ ក្នុងប្រទេសកម្ពុជា។




ក្នុងនាមជា ក្រុមហ៊ុនបុត្រសម្ព័ន្ធ នៅប្រទេសកម្ពុជា របស់ក្រុមហ៊ុន BNK Capital ពួកយើង គឺជាគ្រឹះស្ថាមីក្រូហិរញ្ញវត្ថុ ក្នុងស្រុកដំបូងគេ ដែលដាក់ឱ្យ ដំណើរការកម្មវិធី បច្ចេកវិទ្យាហិរញ្ញវត្ថុ លើទូរស័ព្ទដៃ ហើយគ្រោងនឹង បន្តរួមចំណែក ដល់ការរីកចម្រើន នៃបច្ចេកវិទ្យាហិរញ្ញវត្ថុ នៅក្នុងប្រទេសកម្ពុជា ដោយចែករំលែកចំណេះដឹង បច្ចេកវិទ្យាហិរញ្ញវត្ថុ របស់ក្រុមហ៊ុន BNK Financial Group ទៅកាន់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ទាំងនៅក្នុងស្រុក និងនៅក្រៅប្រទេស។


សំណេះសំណាលជាមួយបុគ្គលិកនៅការិយាល័យកណ្តាល

បុគ្គលិក គ្រប់ជាន់ថ្នាក់ របស់ BNKC MFI ពិតជាមាន សេចក្តីសោមនស្សរីករាយ ចំពោះ វត្តមាន របស់លោកអគ្គនាយក និងនាយកប្រតិបត្តិ រួមទាំង ក្រុមការងារអមដំណើរ ទាំងអស់។ យើងទាំងអស់គ្នា នឹងខិតខំ ជំរុញប្រតិបត្តិការ និងស្វែងរកដំណោះស្រាយ អោយមានប្រសិទ្ធភាព លើបញ្ហា ចំពោះមុខ និងពង្រឹងអាជីវកម្មហិរញ្ញវត្ថុ របស់យើង ដើម្បី សម្រេចបានលទ្ធផលល្អបំផុត ក្នុងពេលបច្ចុប្បន្ន រហូតដល់អនាគត។


ទស្សនាប្រាសាទអង្គរវត្ត


ទស្សនាប្រាសាទតាព្រហ្ម

# ទំនួលខុសត្រូវផ្នែកសង្គម

## កម្មវិធី HAPPY SHARING

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ BNKC (Cambodia) Plc រៀបចំ យុទ្ធនាការ " ចែករំលែក ដោយរីករាយ " ប្រចាំឆ្នាំ របស់ខ្លួន ដើម្បីបង្ហាញពីក្តីស្រលាញ់ ការគាំទ្រ និងក្តីបារម្ភ ចំពោះ សុខុមាលភាពសង្គម។ កាលពី ថ្ងៃសុក្រទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៣ កន្លងទៅនេះ គ្រឹះស្ថានបានចុះទៅដល់ សាលាបឋមសិក្សាតាំងហោង មានទីតាំង ស្ថិតនៅជាប់ជួរ ភ្នំឱរ៉ាល់ ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ដើម្បី ធ្វើការចែកជូន នូវសម្ភារៈសិក្សា សម្ភារៈកីឡា សំលៀកបំពាក់ បរិក្ខារក្មេងលេង (ទោងយោល) និងប្រាក់ឧបត្ថម្ភមួយចំនួន ដល់សិស្សានុសិស្ស និងលោកគ្រូអ្នកគ្រូ នៅទីនោះ។


ប៊ីអេនខេស៊ី ជាដៃគូអាជីវកម្មល្អបំផុតរបស់អ្នក!



សាលាបឋមសិក្សាតាំងហោង ស្ថិតក្នុងស្រុកថ្ពង ខេត្តកំពង់ស្ពឺ



ថតរូបអនុស្សាវរីយ៍

ទោះបី ការចែករំលែកនេះ ជាអំណោយ បន្តិចបន្តួច តែយើងទាំងអស់គ្នា ដែលជាគណៈគ្រប់គ្រង ក៏ដូចជា បុគ្គលិកគ្រឹះស្ថាន ទាំងអស់សង្ឃឹមថា វានឹងជួយរួមចំណែក មួយផ្នែកដល់តម្រូវការ របស់សិស្សានុសិស្ស ក៏ដូចជាផ្តល់ នូវកំលាំងចិត្តដល់សិស្សានុសិស្ស ទាំងអស់ ឱ្យខិតខំ ប្រឹងប្រែងសិក្សា និងបន្តក្តីសង្ឃឹម របស់ពួកគេ។ គ្រឹះស្ថាន នឹងបន្ត ខិតខំ ប្រឹងប្រែងបង្កើតនូវ សកម្មភាព ចែករំលែកក្នុងសង្គម សហគមន៍ និងដល់សិស្សានុសិស្ស ដែលជួបប្រទះ ការលំបាក នៅឆ្នាំ បន្តបន្ទាប់ទៀត។



ពិធីប្រគល់អំណោយជូនសាលា


ចែករំលែកសកម្មភាពសប្បាយរីករាយជាមួយសិស្សានុសិស្ស


ឧបត្ថម្ភថវិការសម្រាប់សិស្សានុសិស្ស


ស្នាមញញឹមរបស់សិស្សានុសិស្ស

# វិញ្ញាបនបត្រអនុលោមភាពសារពើពន្ធ

## ទទួលបានកម្រិតអនុលោមភាពសារពើពន្ធប្រភេទៈ មាស

វិញ្ញាបនបត្រ នៃការអនុលោមតាមនេះ គឺជាសក្ខីភាពមួយ ចំពោះការ ខិតខំប្រឹងប្រែង និងការលះបង់ របស់បុគ្គលិករបស់យើង ក្នុងការបំពេញតាម ការរំពឹងទុក របស់អ្នកពាក់ព័ន្ធ ទាំងអស់ ព្រមទាំង គ្រឹះស្ថាន របស់យើងទាំងមូល។

នេះក៏បង្ហាញថា អាជីវកម្ម បានគោរពពេលវេលាកំណត់ នៃការដាក់ឯកសារ សម្រាប់ពន្ធប្រចាំត្រីមាស និងប្រចាំឆ្នាំ ហើយបានបង់ពន្ធគ្រប់ចំនួន ត្រឹមត្រូវទាន់ពេលវេលា។ វាក៏ជាសញ្ញាបង្ហាញថា ក្រុមហ៊ុនមានជំហរ និងសហការ យ៉ាខ្ជាប់ខ្ជួនជាមួយ អគ្គនាយកដ្ឋានពន្ធដារ និងអ្នកពាក់ព័ន្ធ ទាំងអស់។

យើងខ្ញុំ សូមថ្លែងអំណរគុណ ចំពោះបុគ្គលិក អតិថិជន និងអ្នកពាក់ព័ន្ធ ដ៏ទៃផ្សេងទៀត សម្រាប់ការប្ដេជ្ញាចិត្ត និងការគាំទ្រ ស្របពេល ដែលយើងបន្តជំរុញ អាជីវកម្ម របស់យើង អោយកាន់តែ ល្អប្រសើរ និងរីកចំរើន។ ការទទួលបានវិញ្ញាបនបត្រអនុលោមតាមច្បាប់ពន្ធ ធ្វើឱ្យយើង ស្ថិតក្នុងជំហររឹងមាំ ដើម្បីបន្តជំរុញ កំណើន និងប្រាក់ចំណេញ ទៅថ្ងៃអនាគត។

គ្រឹះស្ថាន ពិតជាមានមោទនភាព ដែលបាន ទទួលស្គាល់លើការប្ដេជ្ញាចិត្ត របស់យើង ចំពោះតម្លាភាព និងការអនុលោមតាមច្បាប់។ សូមអបអរសាទរ ចំពោះគ្រឹះស្ថាន និងបុគ្គលិកទាំងមូល!


MINISTRY OF ECONOMY AND FINANCE
GENERAL DEPARTMENT OF TAXATION

KINGDOM OF CAMBODIA
NATION RELIGION KING

GENERAL DEPARTMENT OF TAXATION

CERTIFICATE OF TAX COMPLIANCE

GENERAL DEPARTMENT OF TAXATION certifies that :

Company's name : BNKC (CAMBODIA) MICROFINANCE INSTITUTION PLC.

Tax Identification Number (TIN) : L001-107034239

Under : Department of large Taxpayers

Business activity(ies) : Micro-finance

Tax Compliance Type awarded : GOLD

Validity period of 2 years for the tax year of 2023 and 2024.

# របាយការណ៍សវនកម្មឯករាជ្យ


របាយការណ៍សវនកម្មឯករាជ្យ ៥០

**របាយការណ៍ហិរញ្ញវត្ថុ**

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ៥៤

របាយការណ៍លទ្ធផលពេញលេញ ៥៥

របាយការណ៍បម្រែបម្រួលមូលធន ៥៦

របាយការណ៍លំហូរសាច់ប្រាក់ ៥៧

# របាយការណ៍របស់សវនករឯករាជ្យ

## ជូនចំពោះ៖ ភាគទុនិករបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេនខេស៊ី (ខេមបូឌា) ភីអិលស៊ី

### មតិយោបល់

យើងខ្ញុំ បានធ្វើសវនកម្មទៅលើ របាយការណ៍ហិរញ្ញវត្ថុ របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេនខេស៊ី (ខេមបូឌា) ភីអិលស៊ី ហៅកាត់ថា (“ក្រុមហ៊ុន”) ដែលរួមមាន របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ របាយការណ៍លទ្ធផលពេញលេញ របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ សម្រាប់កាលបរិច្ឆេទបញ្ចប់ និងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ រួមទាំងសេចក្តីសង្ខេប នៃគោលនយោបាយគណនេយ្យសំខាន់ៗ។

តាមមតិយោបល់ របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុ បានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវ លើស្ថានភាពហិរញ្ញវត្ថុ របស់ក្រុមហ៊ុន នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់ សម្រាប់ការបរិច្ឆេទបញ្ចប់ ដោយអនុលោមតាមស្តង់ដា របាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម (“CIFRS for SMEs”)។

### មូលដ្ឋានក្នុងការបញ្ចេញមតិយោបល់

យើងខ្ញុំ បានធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដា សវនកម្មអន្តរជាតិនៃកម្ពុជា (“CISAs”)។ ការទទួលខុសត្រូវ របស់យើងខ្ញុំ ក្រោមស្តង់ដាទាំងនោះ ត្រូវបានបរិយាយបន្ថែម នៅក្នុងផ្នែកនៃ ការទទួលខុសត្រូវរបស់សវនករ ចំពោះសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ នៃរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំមានឯករាជ្យភាពពីក្រុមហ៊ុន ដោយយោងទៅតាមក្រមសីលធម៌វិជ្ជាជីវៈ សម្រាប់គណនេយ្យករជំនាញ និងសវនករប្រតិស្រុត ដែលចេញដោយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃកម្ពុជា រួមជាមួយនឹងតម្រូវការផ្នែក សីលធម៌ ដែលទាក់ទងទៅនឹងការងារសវនកម្មរបស់យើងខ្ញុំ លើរបាយការណ៍ហិរញ្ញវត្ថុ ក្នុងប្រទេសកម្ពុជា ហើយយើងខ្ញុំ ក៏បានបំពេញនូវទំនួលខុសត្រូវ ដទៃទៀត តាមតម្រូវការទាំងនេះផងដែរ។ យើងខ្ញុំ ជឿជាក់ថា ភស្តុតាងសវនកម្ម ដែលយើងខ្ញុំទទួលបាន មានលក្ខណៈគ្រប់គ្រាន់ និងសមស្រប ដើម្បីផ្តល់ជាមូលដ្ឋាន ក្នុងការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។

### ព័ត៌មានផ្សេងៗ

ព័ត៌មានផ្សេងៗ ដែលបានទទួល នាកាលបរិច្ឆេទ នៃរបាយការណ៍របស់សវនករ រួមមានរបាយការណ៍ របស់ក្រុមប្រឹក្សាភិបាលចាប់ពីទំព័រ ទី១ ដល់ទំព័រទី៥។ គណៈគ្រប់គ្រង គឺជាអ្នកទទួលខុសត្រូវ លើព័ត៌មានផ្សេងៗ។ មតិយោបល់របស់យើងខ្ញុំ លើរបាយការណ៍ហិរញ្ញវត្ថុ ពុំគ្របដណ្តប់លើព័ត៌មានផ្សេងៗនេះទេ ហើយយើងខ្ញុំ ក៏មិនបង្ហាញសេចក្តីសន្និដ្ឋាន បែបធានាអះអាងក្នុងទម្រង់ណាមួយ ទៅលើព័ត៌មានផ្សេងៗ នេះដែរ។

**ព័ត៌មានផ្សេងៗ (តពីទំព័រមុន)**

ទាក់ទងនឹងការងារសវនកម្មរបស់យើងខ្ញុំ លើរបាយការណ៍ហិរញ្ញវត្ថុ ទំនួលខុសត្រូវរបស់យើងខ្ញុំ គឺការអានព័ត៌មានផ្សេងៗនេះ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនេះ មានភាពខុសគ្នាជាសារវន្ត ឬទេ ជាមួយនឹង របាយការណ៍ហិរញ្ញវត្ថុ ឬ ចំណេះដឹងរបស់យើងខ្ញុំ ដែលទទួលបានពីការងារសវនកម្ម ឬ ថាតើព័ត៌មានផ្សេងៗនេះ មានកំហុសឆ្គងជាសារវន្ត ឬទេ។ ប្រសិនបើយើងខ្ញុំ សន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្ត លើព័ត៌មានផ្សេងនេះ យើងខ្ញុំតម្រូវឲ្យរាយការណ៍ តាមភាពជាក់ស្តែង។ យើងខ្ញុំ ពុំមានអ្វី ដែលត្រូវរាយការណ៍ចំពោះ ព័ត៌មានផ្សេងនេះទេ។

## ការទទួលខុសត្រូវ របស់គណៈគ្រប់គ្រង និងអ្នកទទួលបន្ទុក លើអភិបាលកិច្ច ចំពោះរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រង ជាអ្នកទទួលខុសត្រូវចំពោះការរៀបចំ និងការបង្ហាញទិដ្ឋភាពពិត និងត្រឹមត្រូវ នៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមទៅតាម CIFRS for SMEs ហើយនិងទទួលខុសត្រូវដូចគ្នាផងដែរ ចំពោះប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងគិតថាមានសារៈប្រយោជន៍ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលពុំមានកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ។ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងជាអ្នកទទួលខុសត្រូវ ក្នុងការវាយតម្លៃលទ្ធភាព និរន្តរភាពអាជីវកម្មរបស់ក្រុមហ៊ុន និងធ្វើការលាតត្រដាង (ប្រសិនបើមាន) នូវបញ្ហាទាំងឡាយណា ដែលទាក់ទងនឹងនិរន្តរភាពអាជីវកម្ម និងការប្រើប្រាស់មូលដ្ឋាននិរន្តរភាពអាជីវកម្មតាមវិធានគណនេយ្យរបស់ក្រុមហ៊ុន លើកលែងតែក្នុងករណី គណៈគ្រប់គ្រងមានបំណងរំលាយ ឬ បញ្ឈប់ប្រតិបត្តិការក្រុមហ៊ុន ឬ ក៏គ្មានមធ្យោបាយជាក់លាក់ណាមួយទៀត ក្រៅពីនេះ។ អ្នកទទួលបន្ទុកលើអភិបាលកិច្ច មានទំនួលខុសត្រូវ ក្នុងការត្រួតពិនិត្យមើលលើដំណើរការនៃការរាយការណ៍អំពីហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## ការទទួលខុសត្រូវ របស់សវនករចំពោះ សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាង ដែលសមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុទាំងមូល មិនមានកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ ហើយធ្វើការចេញផ្សាយរបាយការណ៍របស់សវនករ ដែលរួមមានមតិយោបល់របស់យើងខ្ញុំ។ ការធានាអះអាងដែលសមហេតុផល គឺជាការធានាអះអាងកម្រិតខ្ពស់មួយ ប៉ុន្តែមិនមែនជាការធានាថាការងារសវនកម្ម ដែលប្រព្រឹត្តទៅ ដោយអនុលោមតាម CISAs តែងតែរកឃើញកំហុសឆ្គងជាសារវន្ត ដែលមាននោះទេ។ កំហុសឆ្គងអាចកើតចេញពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ និងត្រូវបានចាត់ទុកថាជាសារវន្ត ប្រសិនបើកំហុសឆ្គងទាំងអស់នោះ (តែមួយ ឬ បញ្ចូលគ្នាជារួម) អាចមានឥទ្ធិពលលើការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ ដោយផ្អែកលើមូលដ្ឋានរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

**ការទទួលខុសត្រូវ របស់សវនករ ចំពោះសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ** ( **តពីទំព័រមុន** )

ជាផ្នែកមួយនៃការងារសវនកម្មដែលអនុលោមតាម CISAs យើងខ្ញុំបានធ្វើការវិនិច្ឆ័យ និងរក្សានូវចម្ងល់ប្រកបដោយវិជ្ជាជីវៈ ក្នុងដំណើរការសវនកម្ម។ យើងខ្ញុំក៏បាន៖

- កំណត់ និងវាយតម្លៃហានិភ័យនៃកំហុសឆ្គងជាសារវន្ត នៃរបាយការណ៍ហិរញ្ញវត្ថុ ដែលបណ្តាលមកពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ បង្កើត និងអនុវត្តនីតិវិធីសវនកម្ម ដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ ហើយប្រមូលភស្តុតាងសវនកម្មឲ្យបានគ្រប់គ្រាន់ និងសមស្រប សម្រាប់ផ្តល់ជាមូលដ្ឋានក្នុងការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំមានកម្រិតខ្ពស់ជាង កំហុសឆ្គង ដែលបណ្តាលមកពីការភាន់ច្រឡំ ព្រោះថាការក្លែងបន្លំអាចពាក់ព័ន្ធនឹងការឃុបឃិត ការបន្លំ ការលុបចេញដោយចេតនា ការរាយការណ៍មិនត្រឹមត្រូវ ឬ មិនគោរពតាមប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។
- ស្វែងយល់ អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការងារសវនកម្ម ដើម្បីបង្កើតជានីតិវិធីសវនកម្ម ដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែ មិនមែនសម្រាប់គោលបំណង ដើម្បីបញ្ចេញមតិយោបល់លើប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុង របស់ក្រុមហ៊ុនទេ។
- វាយតម្លៃភាពសមស្របនៃគោលនយោបាយគណនេយ្យ ដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ និងការបង្ហាញដែលជាប់ទាក់ទងផ្សេងទៀត ដែលធ្វើឡើងដោយគណៈគ្រប់គ្រង។
- ធ្វើសេចក្តីសន្និដ្ឋាន ទៅលើភាពសមស្រប នៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពអាជីវកម្ម របស់គណៈគ្រប់គ្រងតាមវិធានគណនេយ្យ និងតាមរយៈភស្តុតាងសវនកម្ម ដែលទទួលបាន យើងខ្ញុំធ្វើការសន្និដ្ឋាន លើវត្តមាននៃភាពមិនប្រាកដប្រជា ជាសារវន្តទាក់ទងនឹងព្រឹត្តិការណ៍ ឬ កាលៈទេសៈទាំងឡាយណា ដែលនាំឲ្យមានការសង្ស័យជាសារវន្ត ទៅលើនិរន្តរភាពនៃដំណើរការអាជីវកម្មរបស់ក្រុមហ៊ុន។ ប្រសិនបើយើងខ្ញុំ សន្និដ្ឋានថាមានវត្តមាននៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំតម្រូវឲ្យទាញចំណាប់អារម្មណ៍ក្នុងរបាយការណ៍សវនករលើកំណត់សម្គាល់ពាក់ព័ន្ធ ដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬ ប្រសិនបើកំណត់សម្គាល់នេះ ពុំមានលក្ខណៈគ្រប់គ្រាន់ទេនោះ យើងខ្ញុំនឹងធ្វើការកែប្រែមតិយោបល់របស់យើងខ្ញុំ។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺពឹងផ្អែកលើភស្តុតាងសវនកម្មដែលទទួលបាន រហូតដល់កាលបរិច្ឆេទរបាយការណ៍សវនករ។ តែទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬ កាលៈទេសៈនាពេលអនាគត ក៏អាចបង្កឲ្យក្រុមហ៊ុន មិនអាចបន្តនិរន្តរភាពរបស់អាជីវកម្មបានផងដែរ។
- វាយតម្លៃការបង្ហាញទូទៅ រចនាសម្ព័ន្ធ និងមាតិកានៃរបាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងកំណត់ សម្គាល់ផ្សេងៗ និងវាយតម្លៃថារបាយការណ៍ហិរញ្ញវត្ថុ តំណាងឲ្យប្រតិបត្តិការ និងព្រឹត្តិការណ៍ ដែលជាមូលដ្ឋាន ដើម្បីសម្រេចបាននូវការបង្ហាញដ៏ត្រឹមត្រូវ។

**ការទទួលខុសត្រូវ របស់សវនករចំពោះ សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ** ( **តពីទំព័រមុន** )

ក្នុងចំណោមបញ្ហាដទៃទៀត យើងខ្ញុំបានទំនាក់ទំនងជាមួយអ្នកទទួលបន្ទុក លើអភិបាលកិច្ចអំពីវិសាលភាពដែលបានគ្រោងទុក និងពេលវេលានៃការងារសវនកម្ម និងរបកគំហើញសំខាន់ៗ រួមបញ្ចូលផងដែរនូវកង្វះខាតសំខាន់ៗ ទៅលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលយើងខ្ញុំរកឃើញក្នុងពេលធ្វើសវនកម្ម។

ខារ ហុង
ដៃគូសវនករ

**អឺនស្ទ៍ អ៊ែន យ៉ាំង (ខេមបូឌា)**
ក្រុមហ៊ុនគណនេយ្យករជំនាញ
សវនករប្រតិស្រុត

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤

| | កំណត់សម្គាល់ | ២០២៣ | | ២០២២ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ ២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ ២) |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ និងសមតុល្យនៅគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ - សុទ្ធ | ៤ | ៨.៣៥១.០០៦ | ៣៤.១១៣.៨៦០ | ១០.២៨៣.២៣៨ | ៤២.៣៣៦.០៩១ |
| ប្រាក់តម្កល់តាមបទប្បញ្ញត្តិ | ៥ | ១.០០០.០០០ | ៤.០៨៥.០០០ | ១.០០០.០០០ | ៤.១១៧.០០០ |
| ឥណទាន និងបុរេប្រទានទៅអតិថិជន | ៦ | ៧០.៩២០.៤៤៤ | ២៨៩.៧១០.០១៤ | ៧៨.៩៥១.៧៧៧ | ៣២៥.០៤៤.៤៦៦ |
| ទ្រព្យសកម្មផ្សេងៗ | ៧ | ២៤៧.៥៩៥ | ១.០១១.៤២៦ | ២០១.៤៨៨ | ៨២៩.៥២៧ |
| ទ្រព្យ និងបរិក្ខារ | ៨ | ១.៤៥២.៦៧៦ | ៥.៩៣៤.១៨១ | ១.៣៣៤.៥៩៤ | ៥.៤៩៤.៥២៣ |
| ទ្រព្យសកម្មអរូបិយ | ៩ | ១.៣៦៩.០០៦ | ៥.៥៩២.៣៩០ | ១.៦០១.១២៤ | ៦.៥៩១.៨២៨ |
| ពន្ធពន្យារជាទ្រព្យសកម្ម | ១០.៣ | ១.០៧៤.២២២ | ៤.៣៨៨.១៩៧ | ៣៨៦.០០៤ | ១.៥៨៩.១៧៨ |
| **ទ្រព្យសកម្មសរុប** | | **៨៤.៤១៤.៩៨៩** | **៣៤៤.៨៣៥.០៦៨** | **៩៣.៧៥៨.២២៥** | **៣៨៦.០០២.៦១៣** |
| **បំណុល និងមូលធន** | | | | | |
| **បំណុល** | | | | | |
| បំណុលពន្ធលើប្រាក់ចំណូលត្រូវបង់ | ១០.២ | - | - | ៧៧៦.៣៥៥ | ៣.១៩៦.២៥៤ |
| ប្រាក់កម្ចី | ១១ | ៦២.០០២.៧៣២ | ២៥៣.២៨១.១៦០ | ៦៦.៨៨៩.៧៤៩ | ២៧៥.៣៨៥.០៩៧ |
| បំណុលផ្សេងៗ | ១២ | ៤៤៧.៩៨៦ | ១.៨៣០.០២៤ | ៤៧០.១៨២ | ១.៩៣៥.៧៣៩ |
| **បំណុលសរុប** | | **៦២.៤៥០.៧១៨** | **២៥៥.១១១.១៨៤** | **៦៨.១៣៦.២៨៦** | **២៨០.៥១៧.០៩០** |
| **មូលធន** | | | | | |
| ដើមទុន | ១៣ | ២០.០០០.០០០ | ៨០.០០០.០០០ | ២០.០០០.០០០ | ៨០.០០០.០០០ |
| ប្រាក់ចំណេញរក្សាទុក | | ១.៩៦៤.២៣១ | ៨.០៥២.១៧០ | ៥.៤០៥.៨១២ | ២២.២០៨.៦១៩ |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | ១៤ | - | - | ២១៦.១២៧ | ៨៧៦.៧៣១ |
| លម្អៀងបង្គរពីការបកប្រែរូបិយប័ណ្ណ | | - | ១.៦៧១.៧១៤ | - | ២.៤០០.១៧៣ |
| **មូលធនសរុប** | | **២១.៩៦៤.២៣១** | **៨៩.៧២៣.៨៨៤** | **២៥.៦២១.៩៣៩** | **១០៥.៤៨៥.៥២៣** |
| **បំណុល និងមូលធនសរុប** | | **៨៤.៤១៤.៩៨៩** | **៣៤៤.៨៣៥.០៦៨** | **៩៣.៧៥៨.២២៥** | **៣៨៦.០០២.៦១៣** |

# របាយការណ៍លទ្ធផលពេញលេញ

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | កំណត់សម្គាល់ | ២០២៣ | | ២០២២ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ ២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ ២) |
| ចំណូលការប្រាក់ | ១៥ | ១៣.៣៧០.១០៩ | ៥៤.៩៥១.១៤៨ | ១២.៨១៣.៦៩៣ | ៥២.៣៦៩.៥៦៣ |
| ចំណាយការប្រាក់ | ១៦ | (៤.៤១៧.៥២៧) | (១៨.១៥៦.០៣៦) | (២.៧០២.០៤៤) | (១១.០៤៣.២៥៤) |
| **ចំណូលការប្រាក់សុទ្ធ** | | **៨.៩៥២.៥៨២** | **៣៦.៧៩៥.១១២** | **១០.១១១.៦៤៩** | **៤១.៣២៦.៣០៩** |
| ចំណាយកម្រៃ និងសេវាជើងសារ | ១៧ | (២១៦.០១៨) | (៨៨៧.៨៣៤) | (៣៤៨.០៧១) | (១.៤២២.៥៦៦) |
| ចំណូលប្រតិបត្តិការផ្សេងៗ | ១៨ | ១.០៧៨.២៨៥ | ៤.៤៣១.៧៥១ | ៦៩២.៤០២ | ២.៨២៩.៨៤៧ |
| **ចំណូលប្រតិបត្តិការសរុប** | | **៩.៨១៤.៨៤៩** | **៤០.៣៣៩.០២៩** | **១០.៤៥៥.៩៨០** | **៤២.៧៣៣.៥៩០** |
| ចំណាយទូទៅ និងរដ្ឋបាល | ១៩ | (៦.៣៤៧.១៨៣) | (២៦.០៨៦.៩២២) | (៥.៥៨៨.៦៧៦) | (២២.៨៤០.៩១៩) |
| (សំវិធានធន) ការកត់ត្រាបញ្ច្រាស់នូវការខាតបង់លើអីមភែមិននៃសមតុល្យនៅគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | | (៤៤.២១៩) | (១៨១.៧៤០) | ១០.៩៦២ | ៤៤.៨០២ |
| សំវិធានធនលើការបាត់បង់ឥណទាននិងបុរេប្រទាន | ៦ | (៧.៦៥១.២០០) | (៣១.៤៤៦.៤៣២) | (១.១៣១.៤៩៤) | (៤.៦២៤.៤១៦) |
| **ចំណេញមុនគិតពន្ធលើប្រាក់ចំណូល** | | (៤.២២៧.៧៥៣) | (១៧.៣៧៦.០៦៥) | ៣.៧៤៦.៧៧២ | ១៥.៣១៣.០៥៧ |
| អត្ថប្រយោជន៍(ចំណាយ)ពន្ធលើប្រាក់ចំណូល | ១០ | ៥៧០.០៤៥ | ២.៣៤២.៨៨៥ | (៥៩៦.៣២៧) | (២.៤៣៧.១៨៨) |
| **(ខាត)ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | **(៣.៦៥៧.៧០៨)** | **(១៥.០៣៣.១៨០)** | **៣.១៥០.៤៤៥** | **១២.៨៧៥.៨៦៩** |
| ចំណូលពេញលេញផ្សេងៗ៖ | | | | | |
| លម្អៀងពីការបកប្រែរូបិយប័ណ្ណ | | - | (៧២៨.៤៥៩) | - | ១.៤៣០.៧៨៦ |
| **(ខាត)ចំណេញ ពេញលេញសរុប** | | **(៣.៦៥៧.៧០៨)** | **(១៥.៧៦១.៦៣៩)** | **៣.១៥០.៤៤៥** | **១៤.៣០៦.៦៥៥** |

## របាយការណ៍បម្រែបម្រួលមូលធន

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | ដើមទុន | | ប្រាក់ចំណេញរក្សាទុក | | ទុនបម្រុងតាមបទប្បញ្ញត្តិ (កំណត់សម្គាល់លេខ ១៤) | | លម្អៀងបង្កពីការបកប្រែរូបិយប័ណ្ណ | សរុប | |
|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ | ២០.០០០.០០០ | ៨០.០០០.០០០ | ៥.៤០៥.៨១២ | ២២.២០៨.៦១៩ | ២១៦.១២៧ | ៨៧៦.៧៣១ | ២.៤០០.១៧៣ | ២៥.៦២១.៩៣៩ | ១០៥.៤៨៥.៥២៣ |
| ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | (៣.៦៥៧.៧០៨) | (១៥.០៣៣.១៨០) | - | - | - | (៣.៦៥៧.៧០៨) | (១៥.០៣៣.១៨០) |
| លម្អៀងពីការបកប្រែរូបិយប័ណ្ណ | - | - | - | - | - | - | (៧២៨.៤៥៩) | - | (៧២៨.៤៥៩) |
| **ខាតពេញលេញសុរប** | **-** | **-** | **(៣.៦៥៧.៧០៨)** | **(១៥.០៣៣.១៨០)** | **-** | **-** | **(៧២៨.៤៥៩)** | **(៣.៦៥៧.៧០៨)** | **(១៥.៧៦១.៦៣៩)** |
| ផ្ទេរចេញពីទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | ២១៦.១២៧ | ៨៧៦.៧៣១ | (២១៦.១២៧) | (៨៧៦.៧៣១) | - | - | - |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | **២០.០០០.០០០** | **៨០.០០០.០០០** | **១.៩៦៤.២៣១** | **៨.០៥២.១៧០** | **-** | **-** | **១.៦៧១.៧១៤** | **២១.៩៦៤.២៣១** | **៨៩.៧២៣.៨៨៤** |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២២ | ១៥.០០០.០០០ | ៦០.០០០.០០០ | ២.២៨០.៨៧៦ | ៩.៤៣៧.០០៥ | ១៩០.៦១៨ | ៧៧២.៤៧៦ | ៩៦៩.៣៨៧ | ១៧.៤៧១.៤៩៤ | ៧១.១៧៨.៨៦៨ |
| ដើមទុនបន្ថែម | ៥.០០០.០០០ | ២០.០០០.០០០ | - | - | - | - | - | ៥.០០០.០០០ | ២០.០០០.០០០ |
| ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | ៣.១៥០.៤៤៥ | ១២.៨៧៥.៨៦៩ | - | - | - | ៣.១៥០.៤៤៥ | ១២.៨៧៥.៨៦៩ |
| លម្អៀងពីការបកប្រែរូបិយប័ណ្ណ | - | - | - | - | - | - | ១.៤៣០.៧៨៦ | - | ១.៤៣០.៧៨៦ |
| **ចំណេញពេញលេញសុរប** | **-** | **-** | **៣.១៥០.៤៤៥** | **១២.៨៧៥.៨៦៩** | **-** | **-** | **១.៤៣០.៧៨៦** | **៣.១៥០.៤៤៥** | **១៤.៣០៦.៦៥៥** |
| ផ្ទេរចូលទៅទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | (២៥.៥០៩) | (១០៤.២៥៥) | ២៥.៥០៩ | ១០៤.២៥៥ | - | - | - |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **២០.០០០.០០០** | **៨០.០០០.០០០** | **៥.៤០៥.៨១២** | **២២.២០៨.៦១៩** | **២១៦.១២៧** | **៨៧៦.៧៣១** | **២.៤០០.១៧៣** | **២៥.៦២១.៩៣៩** | **១០៥.៤៨៥.៥២៣** |

| | កំណត់សម្គាល់ | ២០២៣ | | ២០២២ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ ២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ ២) |
| **សកម្មភាពប្រតិបត្តិការ** | | | | | |
| (ខាត) ចំណេញមុនគិតពន្ធលើប្រាក់ចំណូល | | (៤.២២៧.៧៥៣) | (១៧.៣៧៦.០៦៥) | ៣.៧៤៦.៧៧២ | ១៥.៣១៣.០៥៧ |
| និយ័តកម្មទៅលើ៖ | | | | | |
| រំលស់ | ៨.៩ | ៦៤០.២៦៥ | ២.៦៣១.៤៨៩ | ៤១៤.១៦២ | ១.៦៩២.៦៨០ |
| សំវិធានធនសម្រាប់ការខាតបង់អឺមតែរមិន | | ៧.៦៩៥.៤១៩ | ៣១.៦២៨.១៧២ | ១.១២០.៥៣២ | ៤.៥៧៩.៦១៤ |
| ខាតពីការលុបចោលនៃទ្រព្យ និងបរិក្ខារ | | ៩៦០ | ៣.៩៤៦ | ១.៤៤០ | ៥.៨៨៥ |
| ខាតពីការលក់ទ្រព្យសកម្មអរូបិយ | | ៣.៧៦៤ | ១៥.៤៧០ | - | - |
| បម្រែបម្រួលក្នុងទ្រព្យ និងបំណុលប្រតិបត្តិការ៖ | | | | | |
| ប្រាក់តម្កល់តាមបទប្បញ្ញត្តិ | | - | - | (២៥០.០០០) | (១.០២១.៧៥០) |
| ឥណទាន និងបុរេប្រទានទៅអតិថិជន | | ៣៨០.១៣៣ | ១.៥៦២.៣៤៧ | (១០.៨៥៦.០៦៦) | (៤៤.៣៦៨.៧៤២) |
| ទ្រព្យសកម្មផ្សេងៗ | | (៦៩.៤២៣) | (២៨៥.៣២៩) | ៥៩.១០០ | ២៤១.៥៤២ |
| បំណុលផ្សេងៗ | | ៥៨.៥៧៣ | ២៤០.៧៣៥ | ២០៤.៥៨៧ | ៨៣៦.១៤៧ |
| **សាច់ប្រាក់ទទួលបានពី (ប្រើប្រាស់ក្នុង) សកម្មភាពប្រតិបត្តិការ** | | **៤.៤៨១.៩៣៨** | **១៨.៤២០.៧៦៥** | **(៥.៥៥៩.៤៧៣)** | **(២២.៧២១.៥៦៧)** |
| ពន្ធលើប្រាក់ចំណូលបានបង់ | ១០.២ | (៩១៣.៧៦៨) | (៣.៧៥៥.៥៨៦) | (៨៤៧.២១៧) | (៣.៤៦២.៥៧៦) |
| **សាច់ប្រាក់សុទ្ធទទួលបានពី (ប្រើប្រាស់ក្នុង) សកម្មភាពប្រតិបត្តិការ** | | **៣.៥៦៨.១៧០** | **១៤.៦៦៥.១៧៩** | **(៦.៤០៦.៦៩០)** | **(២៦.១៨៤.១៤៣)** |
| **សកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យ និងបរិក្ខារ | ៨ | (៥៨៤.២១៦) | (២.៤០១.១២៨) | (៨៧០.៩១៦) | (៣.៥៥៩.៤៣៤) |
| ការទិញទ្រព្យសកម្មអរូបិយ | ៩ | (៦.៧៣៧) | (២៧.៦៨៩) | (៣៣៥.៣០៦) | (១.៣៧០.៣៩៦) |
| ចំណូលពីការលក់ទ្រព្យអរូបិយ និងទ្រព្យ និងបរិក្ខារ | ៩ | ៦០.០០០ | ២៤៦.៦០០ | ១១.៤៩៩ | ៤៦.៩៩៨ |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | | (៥៣០.៩៥៣) | (២.១៨២.២១៧) | (១.១៩៤.៧២៣) | (៤.៨៨២.៨៣២) |
| **សកម្មភាពហិរញ្ញប្បទាន** | | | | | |
| ការដាក់ប្រាក់បញ្ញើមានកាលកំណត់ | | (១.៦៤០.១៤៧) | (៦.៧៤១.០០៤) | - | - |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | ១១ | ២០.០០០.០០០ | ៨២.២០០.០០០ | ២១.០០០.០០០ | ៨៥.៨២៧.០០០ |
| ការទូទាត់ប្រាក់កម្ចី | ១១ | (២៤.៩៤៨.៣៣០) | (១០២.៥៣៧.៦៣៦) | (១១.១១៤.៥៦៩) | (៤៥.៤២៥.២៤៤) |
| សាច់ប្រាក់បានពីការបន្ថែមមូលធន | ១៣ | - | - | ៥.០០០.០០០ | ២០.៤៣៥.០០០ |
| **សាច់ប្រាក់សុទ្ធ (ប្រើប្រាស់ក្នុង) ទទួលបានពីសកម្មភាពហិរញ្ញប្បទាន** | | **(៦.៥៨៨.៤៧៧)** | **(២៧.០៧៨.៦៤០)** | **១៤.៨៨៥.៤៣១** | **៦០.៨៣៦.៧៥៦** |
| ការ(ថយចុះ)កើនឡើងសុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល | | (៣.៥៥១.២៦០) | (១៤.៥៩៥.៦៧៨) | ៧.២៨៤.០១៨ | ២៩.៧៦៩.៧៨១ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាដើមការិយបរិច្ឆេទ | | ១០.៣០០.៣៦៥ | ៤២.៤០៦.៦០២ | ៣.០១៦.៣៤៧ | ១២.២៨៨.៥៩៧ |
| លម្អៀងពីការបកប្រែរូបិយប័ណ្ណ | | - | (២៤០.៨២៩) | - | ៣៤៨.២២៤ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងការិយបរិច្ឆេទ** | ៤ | **៦.៧៤៩.១០៥** | **២៧.៥៧០.០៩៥** | **១០.៣០០.៣៦៥** | **៤២.៤០៦.៦០២** |



# ទាក់ទងមកយើងខ្ញុំ
# សម្រាប់ព័ត៌មានបន្ថែម

hq.bnkcc@c.bnkcapital.com | 023-213-900 | www.bnkcmfi.com